# ការសំភាសន៏របស់អ៊ំស្រី ឡឹក រស់

កៈ ធ្វើការសំភាសន៏ដោយខ្ញុំបាទអ៊ុំ ប្រសិទ្ធ   ខៈ អ្នកត្រូវបានគេសំភាសន៏អ៊ំស្រី ឡឹក រស់

**<u>ការសង្ខេបអំពីជីវប្រវត្តរបស់អ៊ំស្រី ឡឹក រស់</u>**

អ៊ំស្រី មានឈ្មោះ ឡឹករស់

មានអាយុ៦៧ឆ្នាំកើតនិងរស់នៅឯកោះដាច់ក្រុងភ្នំពេញគាត់មកពីក្រុមគ្រួសារដែលខ្វះខាត គាត់បានរៀនបានតិចតួចគាត់ជាអ្នកតំម្បាញជិវិតរបស់គាត់មានការតស៊ូច្រើនណាស់៕

កៈ អញ្ចឹងជាមុនដំបូងសូមជំរាបសួរ។

ខៈ ចាំ។

កៈ អ៊ំស្រី។

ខៈ ចាំ។

កៈ

អញ្ចឹងខ្ញុំមកពីម្នាក់ងារមួយខាងសាលាប៊ីបាយយ៉ូនៅសហរដ្ឋអាមេរិចអញ្ចឹងពួកយើងមានទិស ដៅនិងគោលបំណងចងក្រងនៅពង្សពង្សប្រវត្តប្រជាជនកម្ពុជារបស់យើង។

ខៈ ចាំ ។

កៈ អញ្ចឹងសំរាប់អ៊ំយល់ព្រមដើម្បីអោយខាងប្អូនធ្វើការសំភាសន៏អ៊ំដែលឬទេ?

ខៈ មានអី។

កៈ បាទ

អញ្ចឹងសំរាប់ថ្ងៃនិងពួកខ្ញុំនិងចាប់ផ្តើមសំភាសន៏ធ្វើការសំភាសន៏ជាមួយអ៊ំនៅថ្ងៃទី១៩ខែឧស ភាឆ្នាំ២០១៨ហើយក៏និងក៏បានធ្វើនៅផ្ទះរបស់អ៊ំនៅលើកោះ។

ខៈ ចាំ។

កៈ លើកោះដាច់និងតែម្តង។

កៈ អញ្ចឹងសំរាប់សំនួរដំបូងរបស់ខ្ញុំគឺចង់សួរអ៊ំថាតើអ៊ំមានឈ្មោះអ្វីដែល?

ខៈ ខ្ញុំឈ្មោះអណ្តែងឡឹករស់។

កៈ អាចថាម្តងទៀតបានទេអ៊ំ?

ខៈ ខ្ញុំឈ្មោះឡឹករស់។

កៈ ឡឹករស់។

ខៈ ចាំ ឡឹករស់។

កៈ បាទ។

ខៈ ចាំ។

កៈ ហើយងអ៊ំមានព្រះជន្មប៉ុន្មានហើយអ៊ំ?

ខ៖ ខ្ញុំមានអាយុសព្វថ្ងៃ៦៥។
ក៖ ៦៥ឆ្នាំ។
ខ៖ ចាំ។
ក៖ អ៊ំមានទីរកន្លែងកំនើតនៅកន្លែងណាដែលអ៊ំ?
ខ៖ ខ្ញុំរស់នៅឯស្រុកក្បាលកោះនិងតែម្តង។
ក៖ ក្បាលកោះ។
ខ៖ ចាំ។
ក៖ និងតែម្តង។
ក៖ ក្បាលកោះនិងត្រូវជាខេត្តកណ្តាលឬក៏ទីរក្រុងភ្នំពេញ?
ខ៖
ឥលូវនេះគេថាកោះដាច់ស្រុកមុខកំពូលខេត្តកណ្តាលតែឥលូវនេះចូលជ្រួយចូលខណ្ឌជ្រួយចង្វារ។
ក៖ ចូលខណ្ឌជ្រួយ។
ខ៖ចាំ។
ក៖ ជ្រួយចង្វារហើយ។
ខ៖ ចាំ ។
ក៖ ចុះអ៊ំមានឪពុកម្តាយឈ្មោះអីគេដែលអ៊ំចាំទេអ៊ំ?
ខ៖ ឪពុកខ្ញុំឈ្មោះតាសាន់។
ក៖ តាសាន់។
ខ៖ ចាំ ម្តាយខ្ញុំឈ្មោះគង់។
ក៖ ឈ្មោះគង់។
ខ៖ ចាំ ឈ្មោះគង់សាន។
ក៖ គង់សាន។
ខ៖ ចាំ ឥលូវនិងពួកគាត់ស្លាប់អស់ហើយ។
ក៖ គេស្លាប់អស់ហើយ។
ខ៖ ពេលគាត់ស្លាប់អាយុ៧៨។
ក៖ ៧៨។
ខ៖ ចាំ។
ក៖ អញ្ចឹងសំរាប់អ៊ំនៅចាំមនុស្សដែលចាស់ជាគាត់ដូចជាជីតួតជីលាជីតាអីអត់?
ខ៖ អត់ចាំផង។
ក៖ អត់ចាំ។

ខ៖ ចាំបានត្រឹមតែម្ដាយឪពុខ្ញុំនិង។
ក៖ បាទ ។
ខ៖ ចា៎ ចាំតែប៉ុន្នឹងទេ។
ក ៖
អ៊ំនៅចាំថាពេលអ៊ំបានចាប់កំណើតនិងពេលអ៊ំចាប់កំណើតនៅមណ្ឌលសុខភាពឬក៏នៅផ្ទះធម្មាឬក៏នៅមន្ទីពេទ្រ?
ខ៖ អ៊ំរកាលណោះនិងគាត់បង្កើតតែនិងឆ្មបខ្មែរ។
ក៖ តាមឆ្មបខ្មែរតាមឆ្មបខ្មែរ។
ខ៖ ចា៎ តាមឆ្មបខ្មែរអត់មានមណ្ឌលអីទេកាលណោះនិង។
ក៖ បាទ។
ខ៖ ចា៎ កាលនិងមានអីណានេះអីគាត់ឃើញយាយម៉បនិងគេចាប់កន្ត្រៃអីនិងកន្ត្រៃយើងនិង។
ក៖ បាទ។
ខ៖ អាកន្ត្រៃខ្មៅកាត់សុកកាត់អីនិង។
ក៖ បាទ។
ខ៖ ចា៎ អត់មានដូចឥលូវមានមណ្ឌលអីគេពិនិត្តសុខភាពអីទេ។
ក៖ មានមណ្ឌលសុខភាព។
ខ៖ ចា៎។
ក៖ ឥលូវគេមាន។
ខ៖ ឥលូវគេមានពេលត្រូវការអីវះកាត់អីវិបៗៗៗ។
ក៖ វិបៗ។
ខ៖ ចា៎ ។
ក៖ អញ្ចឹងអ៊ំនៅចាំពីទីរកន្លែងកំនើតរបស់ឪពុកម្ដាយអ៊ំទេ?
ខ៖ គាត់នៅនិង។
ក៖ គាត់នៅនិងដូចគ្នា។
ខ៖ នៅនិង។
ក៖នៅ ភូមិស្រុកកោះដាច់និងដូចគ្នា។
ខ៖ ស្រុកកោះដាច់។
ក៖ កោះដាច់និងដូចគ្នា។
ក៖ អញ្ចឹងអ៊ំនៅចាំថានៅពេលអ៊ំកើតនិងអ៊ំកើតនៅពេលព្រឹកឬក៏ពេលថ្ងៃឬក៏ពេលយប់។
ខ៖ អ៊ំពេលខ្ញុំកើតខ្ញុំអត់ដឹងផង។
ក៖ អត់ដឹងទេ។

ខ៖ ភ្លេចហើយចាំ។
ក៖ បាទអ្នកមីង។
ក៖ អញ្ចឹងអ៊ំនៅចាំឆ្នាំដែលអ៊ំកើតទេ?
ខ៖ ខ្ញុំនិងវាឆ្នាំមមីរ។
ក៖ ឆ្នាំមមីរជាឆ្នាំខ្មែរ។
ខ៖ ចាំ។
ក៖ ចុះឆ្នាំបារាំងវិញ?
ខ៖ ខ្ញុំអត់ដឹងទេ។
ក៖ អត់ដឹង។
ខ៖ ចាំ ខ្ញុំដឹងថាឆ្នាំមមីរ។
ក៖ ឆ្នាំមមីរ។
ខ៖ ហើយរាល់ថ្ងៃនិងខ្ញុំ៦៥។
ក៖ ៦៥។
ខ៖ ចាំ។
ក៖ អញ្ចឹងខ្ញុំគិតថាប្រហែលជាអ៊ំកើតនៅឆ្នាំ១៩៦០ជាងប៉ុន្តែមិនដឹងថាកើត។
ខ៖ ដឹងអីបើខ្ញុំវាអត់ចាំចាំតែខ្មែរ។
ក៖ បាទ
អញ្ចឹនៅពេលអ៊ំកើតក្នុងចខែក្នុងសមយ័អីគេដែលគេហៅថារបបអីគេមួយដែលនៅក្នុងសមយ័និង។
ខ៖
និយាយពីខ្ញុំកើតនិងខ្ញុំវាអត់កាលនិងខ្ញុំអត់ទាន់ជំនាន់ពីណាទេជំនាន់និងលនណុលក៏មិនមែន
។
ក៖ ក៏មិនមែន។
ខ៖ ចាំ និងគេតែងតែហៅថាស្អីគេនិងហ្មុំកាលពីមុន។
ក៖ សង្គមរាសនិយម។
ខ៖ សង្គមរាស្រ្តពួកអីគេទេជំនាន់។
ក៖ បាទ។
ខ៖ ខ្ញុំអត់ទាន់ដែល។
ក៖ បាទ។
ខ៖ ចាំ។

ក៖
អញ្ចឹងនិយាយពីការចូលរៀនវិញនៅពេលអ៊ំនៅសមយ័ដែលអ៊ំកើតហើយបានអាយុប្រាំប្រាំមួយឆ្នាំអីអ៊ំមានឧកាសបានចូលរៀននៅសមយ័លុណនុលនិងអត់។
ខ៖ ខ្ញុំបានរៀននៅក្នុងជំនាន់លុណនុល។
ក៖ បារតរៀនក្នុងជំនាន់លុណនុល។
ខ៖ ចាំខ្ញុំបានរៀនតែកាលតិចណាស់បានបួនថ្នាក់។
ក៖ បាទ បានបួនថ្នាក់។
ខ៖ ចាំ។
ក៖ កាលពីជំនាន់មុនគេរាប់ថ្នាក់ពីលេខធំទៅលេងតូច?
ខ៖ ពីលេខ១២៣៤។
ក៖ លេង៣ថ្នាក់ទី១។
ខ៖ ថ្នាក់ទីរមួយ ថ្នាក់ទីរពីរ ថ្នាក់ទីរបី ថ្នាក់ទីរបួន ។
ក៖ ថ្នាក់ទីរបួនចឹងម៉ង។
ខ៖ ព្រោះតែម៉ែឪខ្ញុំក្រខ្ញុំអត់បានរៀនអីច្រើនទេបានត្រឹមតែប៉ុន្នឹង។
ក៖ បាទបាទបាទ។
ខ៖ ចាំ អញ្ចឹងខ្ញុំខំប្រឹងថ្បាញអីនិងណា។
ក៖ បាទអ៊ំបាទ។
ខ៖ ខំត្បាញចញ្ចឹមជិវិតធ្វើត្បាញហើយក៏គាត់ជាអ្នកធ្វើចំការ។
ក៖ បាទ។
ខ៖ ហើយខ្ញុំក៏ជាតំបាញនិងណា។
ក៖ បាទ។
ខ៖ ហើយខ្ញុំអាយុ១៧ហើយប្តីខ្ញុំនិងអាយុ២២។
ក៖ បាទ។
ខ៖ ហើយមានលោកតាក្បាលកោះគាត់មកដណ្តឹងភ្ជាប់ពាក្រភ្ជាប់អីទៅ។
ក៖ បាទ។
ខ៖ មិនដូចជាក្មេងតលូវគេខំប្រឹងរៀនខំសូត្ររហូតដល់អាយុ២០ជាងនោះទេនិងណា។
ក៖ បាទបាទបាទ។
ខ៖ ចាំ ។
ក៖ អញ្ចឹងនៅពេលដែលអ៊ំរៀនអ៊ំគិតថាអ៊ំខ្លាំងខាងមុខវិជ្ជាអីគេជាគេដែល។
ខ៖ អ៊ើរខ្ញុំត្បាញ។
ក៖ ផ្នែកត្បាញនិងតែម្តង។

ខ៖ ចាំ
ផ្នែកត្បាញនិងតែម្ដងខ្ញុំស្រលាញ់ត្បាញក្រមារួចហើយត្បាញក្រមារអញ្ចឹងទៅក៏ត្បាញផាមួង
ទៅ។
ក៖ បាទផាមួង។
ខ៖ លើកជរអីចឹងទៅ។
ក៖ បាទ ។
ខ៖ ចាំ។
ក៖
ចុះការសិក្សាដូចជារៀនភាសារខ្មែរអីគណិតវិទ្យាឬក៏ផ្នែកភាសារបរទេសបារាំងឬក៏អង្គលេស
នៅជំនាន់និងអ៊ំមានពូកែទេ?
ខ៖ អត់ទេអត់ទេ។
ក៖ អត់ពូកែខាងនិងទេ។
ខ៖ ចាំខ្ញុំរៀនត្រឹមថ្នាក់ទីរ៩មិនមានទាន់បានរៀនបារាំងពីណា។
ក៖ បាទ
អ៊ំអាចរៀបរាប់ពីទិដ្ឋភាពនៅសមយ័នៅជាវយ័កុមារតើអ៊ំមានការស្លៀតពាក់ប្រភេទអីគេដែល
កាលស្លៀកពាក់ជំនាន់និងគេស្លៀកពាក់ប្រភេទអីកេដែលសិស្សសាលា?
ខ៖ អ៊ឺរកាលនិងសិស្សសាលាគេស្លៀកសំពត់ខៀវអាវស។
ក៖ សំពត់ខៀវអាវស។
ខ៖ ចាំ ហើយទៅម៉ែឪខ្ញុំក្រអត់មានទេព្រោះសំពត់និងពេលមកពិរៀនវិញនិងយកមកគក់។
ក៖ បាទ។
ខ៖ យកមកគក់ហាលហើយព្រលឹមឡើងស្លៀកមកទៀត។
ក៖ បាទ។
ខ៖ អត់មានបានច្រើនអីផ្លាស់អីទេដូចជាគេចឹងទេ។
ក៖ ដូចជាគេចឹងទេ។
ខ៖ ចាំ។
ក៖
អញ្ចឹមធ្យោលបាយធ្វើដំណើរនៅក្នុងសមយ័និងពេលទៅសាលានិងទៅតាមរយះអីគេដែល?
តាមរយះដើឬក៏មានកង់អីគេជិះ?
ខ៖អ៊ឺរកាលនិងខ្ញុំអត់មានកង់ជិះទៅដើរដើរ។
ក៖ ដើរ។
ខ៖ ចាំ។

ក៖ តើចំងាយពីសាលាពីផ្ទះប្រហែលជាឆ្ងាយឬក៏ជិត?
ខ៖ ឆ្ងាយដែល។
ក៖ ឆ្ងាយដែល។
ខ៖ និងហើយឆ្ងាយ។
ក៖
អ៊ំនៅចាំពីស្ថានភាពគ្រូបង្រៀននៅក្នុងសម័យនិងអត់ដូចជាគាត់ផ្តល់ក្តីស្រលាញ់ច្រើនដល់កូនសិស្សគ្រប់ៗគ្នាឬក៏?
ខ៖
អឺរគាត់សិស្សគ្រូបង្រៀនគាត់កាលនិងគាត់មិនសូវជាអ្នកមានប៉ុន្មានទេគាត់រច្រើនជាអ្នកចាក់អាប៉ោងគាត់ច្រើនជាមានស្រីញី។
ក៖ បាទ។
ខ៖ ចាំ មោនសូវជាពូកែដូចជាគ្រូៗៗៗសមយ័ឥលូវនិងទេ។
ក៖ បាទ។
ខ៖ ចាំ ។
ក៖
ចុះនៅពេលដែលអ៊ំរៀនអ៊ំគឺជាក្មេងដែលក្លាចក្នុងកាលរៀនឬក៏ជាក្មេងដែលឧស្សាហ៍ក្នុងកាលរៀន?
ខ៖
ខ្ញុំខំប្រឹងរៀនប្រឹងសូត្រចឹងដែលប៉ុន្តែកាលហ្នោះម៉ែពុកខ្ញុំគាត់ក្រមិនអាចអោយខ្ញុំតស៊ូទៅបានគាត់អោយឈប់ទៅរៀន។
ក៖ បាទ។
ខ៖ ឈប់ត្បាញ។
ក៖ ឈប់ត្បាញចឹងទៅ។
ខ៖ ចាំ ។
ក៖ បាទ
សំរាប់អ៊ំទៅលើចំនង់ចំនូលចិត្តអ៊ំកាលពេលនៅក្នុងវយ័ក្មេងនិងសំរាប់អ៊ំតើអ៊ំចូលចិត្តអីជាងគេនៅក្នុងជំនាន់និងនៅពេលក្នុងវយ័កុមារនិង។
ខ៖ ខ្ញុំចូលចិត្តត្បាញ។
ក៖ ខ្ញុំចូលចិត្តត្បាញនិង។
ខ៖ ចាំ ស្រុកខ្ញុំស្រុកកោះដាច់និងត្បាញតែជាមួងនិង។
ក៖ បាទ។

ខ៖ ចាំ ។
ក៖ ពណ៌អីដែលអ៊ំចូលចិត្តជាងគេអ៊ំ?
ខ៖
ពណ៌ផ្ទៃខ្មៅចាក់ផ្ទៃខ្មៅចាក់ពណ៌ទឹកប៊ិចផ្កាឈូកចាក់ពណ៌សពណ៌សនិងទៅជាពណ៌ប្រភេះនិងណា។
ក៖ បាទអ៊ំ។
ខ៖ គេទិញយកទៅច្រើនស្រុកបារាំងកាលមុននិងធ្វើចំនិញណាស់ម៉ាកីៗៗៗនិងណា។
ក៖ បាទ។
ខ៖ ម៉ាកីម៉ាកីនិងក្នុងម៉ាកីនិង១០០០ដូឡា។
ក៖ បាទ បាទ
ចុះអ៊ំមានទេពកោសលខាងត្បាញនិងតើកាលរៀនអំពីរបៀបត្បាញនិងប្រើរយះពេលយូលទេអ៊ំ?
ខ៖ ត្បាញនិងខ្ញុំត្បាញតាំងពីខ្ញុំអាយុ១២ម្លេះ។
ក៖ អាយុ១២ម្លេះ។
ក៖ ១២ឆ្នាំ។
ខ៖ ចាំ ត្បាញអាយុ១២រហូតខ្ញុំដល់អាដែង១៧ខ្ញុំការ។
ក៖ បាទ។
ខ៖ ហើយការរួចខ្ញុំនិងរហូតខ្ញុំមានអាយុ៥០ក៏ខ្ញុំនៅតែត្បាញដែល។
ក៖ បាទ ។
ខ៖ ទើបអាលូវនិងខ្ញុំ៦៥ភ្នែកចាស់ពែកហាហើយវាអត់កើតនិងណា។
ក៖ បាទ។
ខ៖ ហើយក៏ឈប់ទៅៗ។
ក៖ បាទ។
ក៖
អញ្ចឹងសំរាប់អ៊ំអាចគិតថានិយាយអំពីជីវប្រវត្តរបស់អ៊ំរបស់ឪពូកម្តាយអ៊ំបន្តិចវិញថាតើស្ថានភាពជីវភាពរបស់អ៊ំនៅក្នុងសម័យនិងថាតើនៅពេលដែលអ៊ំមានអាយុប្រាំមួយពប្រាំពីឆ្នាំនិងថាតើជីវភាពក្រុមគ្រួសារអ៊ំយ៉ាងម៉ិចដែល?
ខ៖ អ៊ំរកាលនិងម៉ែឪខ្ញុំគាត់ករណាស់។
ក៖ ក្រ។
ក៖ ឪពុករបស់អ៊ំគាត់ធ្វើការអីគេដែល?
ខ៖ ឪពុកខ្ញុំគាត់ធ្វើឪពុកខ្ញុំគាតើស្លាប់តាំពីខ្ញុំអត់ស្គាល់មុខគាត់។

កៈ អត់ស្គាល់មុខគាត់។
កៈ ចុះសំរាប់ម្ដាយវិញ?
ខៈ ស្លប់ឪពុក។
កៈ សំរាប់ម្ដាយវិញ។
ខៈ ស្លាប់ឪពុកខ្ញុំអត់ស្គាល់ឪពុកខ្ញុំអត់ដឹងថាគាត់មានមុខយ៉ាងម៉ិចទេ។
កៈ បាទ ។
កៈ ចុះម្ដាយនៅតែម្នាក់ឯង។
ខៈ ម្ដាយខ្ញុំស្គាល់។
កៈ បាទ។
ខៈ
ស្គាល់គាត់រហូតដល់ពេលគាត់ស្លាប់និងព្រះជន្មគាត់ស្លាប់នៅក្នុងនិងដៃខ្ញុំនិងគាត់ព្រះជន្មគាត់គាត់មានអាយុ៧៨។
កៈ អាយុ៧៨។
ខៈ ចុះម្ដាយរបស់អ៊ំគាត់បានប្រកបមុខរបរអីដើម្បីប្រកបមុខរបរចញ្ចឹមអ៊ំរហូតដដល់ឥលូវ?
ខៈ
ម៉ែខ្ញុំនិងមុខរបរគាត់ចេះតែត្បាញកន្ទេលត្បាញអីចឹងទៅចឹងដើរកាប់អុសកាប់អីនិងទៅនិងទៅចញ្ចឹម។
កៈ បាទអ៊ំ។
ខៈ កូនរហូតដល់តែបី។
កៈ បាទ។
ខៈ ខ្ញុំមានបងប្អូនបីអ្នក។
កៈ បីអ្នក។
ខៈ ចាំ ។
កៈ មានឈ្មោះអីគេដែលអ៊ំ?
ខៈ មួយមានឈ្មោះឡឹកសារឿន។
កៈ ឡឹកសារឿន។
ខៈ មួយទៀតឡឹកសារិនបងបង្អស់ទីរពីឡឹកសារឿន។
កៈ ឡឹកសារឿន។
ខៈ មកខ្ញុំនិងឡឹករស់។
កៈ ឡឹករស់។
ខៈ ចាំ ។

កៈ ពួកគាត់នៅមានជិវិតរហូតដល់ឥលូវ?
ខៈ ពួកគាត់បងខ្ញុំគាត់ស្លាប់នៅក្នុងជំនាន់អាពត។
កៈ បងបង្អស់ស្លាប់នៅក្នុងជំនាន់ពុលពតហើយស្លាប់ដោយសារអីគេដែល?
ខៈ អាពតវាយកទៅសំលាប់ចោល។
ខៈ ហើយទីរពីស្លាលប់ដោយសារតែធ្វើទាហ៊ាន។
កៈ បាទ ។
កៈចុះបងមមួយទៀត។
ខៈ ខ្ញុំអត់នៅ  បងខ្ញុំគាត់ស្លាប់នៅក្នុងសមយ័លុណុលគាត់ចាញ់ធ្វើជាទាហ៊ាន។
កៈ បាត។
ខៈ ចាំ ។
កៈ អញ្ចឹឥលូវអ៊ំនៅគ្មានបងប្អូនបង្កើតទេ?
ខៈ ទេខ្ញុំអត់មានទេនៅតែឯទេពួកគេស្លាប់អស់ហើយ
កៈ នៅតែឯងទេ។
កៈ អញ្ចឹងអ៊ីរ។
ខៈ គេស្លាប់អស់ហើយ។
កៈ
អ៊ំយើងនិងរំលងពីអានិងមកពីអាសមយ័ដែលអ៊ំនៅរៀននិងចូលមកដល់សមយ័ពលពតវិញអ៊ំនៅចាំអំពីទិដ្ឋភាពដើមដំបូងពីការដែលជំលាសឬក៏ការដែលកើតមាននៅសមយ័ពុលពតនិងអត់នៅចាំអត់?
ខៈ កាលពីអាពតវាជំលាសខ្ញុំទៅនិងវាជំលាសចិញពីកោះទៅទៅពោសាតធ៏។
កៈ ទៅពោសាធន៏។
ខៈ ចាំ
គេអោយស្ទូងគេអោយដកអីចឹងទៅហើយពេលនិងខ្ញុំក៏មានកូនមួយទៀតដល់ពេលកូនមួយទៀតនិងវាម៉ោងពីរអីនិងវាបំបែកជួរអីនិងកូនដោយកូនម៉ែដោយម៉ែ។
កៈ បាទ។
ខៈ អោយទៅស្ទូងទៅដករួចដល់ពេលដែលក្នុងមួយថ្ងៃគេចែកបបរអោយ។
កៈ បាទ។
ខៈ មួយវែកៗៗៗម្នាក់ចាំ។
កៈ
អញ្ចឹខ្ញុំចង់កាត់អ៊ំបន្តិចដោយសារខ្ញុំរាងអត់សូវយល់អ៊ំរាបការជាមួយនិងប្តីរបស់អ៊ំពីមុននិងមានពុលពតឬក៏ក្នុងសមយ័ពុលពត?

ខ៖ អ៊ុំ រជំនាន់លុណនុល។
ក៖ ជំនាន់លុនណុល។
ខ៖ ចា៎។
ក៖
អ្ហចឹងអ៊ំមានអាយុមានថានៅពេលដែលបែលកពុលពតអ៊ំគឺជាមនុស្សពេញវយ័ដែលហើយ។
ខ៖ ចា៎ ។
ក៖ បាទ។
ក៖
អញ្ចឹនៅពេលគេដែលគេជំលាសគេជំលាសជាគ្រួសារឬក៏មាននយ័ថាគ្រួសារប្តីប្រពន្ធមហើយ
និងឪពុកម្តាយជាមួយនិងម្តាយឬក៏ទៅជាមួយគ្នានិង?
ក៖ ជំលាសនិងដែកដូចជាខ្ញុំបាននិយាយចឹងប្តីខ្ញុំនិងគាត់បានបែកខ្ញុំទៅឯរកត្រីនិង។
ក៖ បាទ។
ខ៖ ទៅនិងហ្មោះគេថា១៨និងណា។
ក៖ បាទ។
ខ៖ ខ្ញុំវា១៧ចឹង។
ក៖ បាទ។
ខ៖ អាពេលបែកភ្នំពេញវិញមកជំគ្នាវិញនិងណា។
ក៖ បាទ។
ខ៖ អាពេលចឹងអាពតចាប់ជំលាសទៅមួយសារទៀត។
ក៖ បាទ។
ខ៖ ចាប់ចេញពីភូមិគេរើសអ្នកដែល១៨អ្នក១៧អ្នក១៨គឺនៅស្រុកនេះ។
ក៖ បាទ។
ក៖ ១៧ទៅនៅស្រុផ្សេង។
ខ៖
គេយកទៅនៅស្រុផ្សេងទេតាមពិតគេមានគំរោងការយកទៅសំលាប់ចោលតែវាធ្វើការអោយវា
មិនទាន់។
ក៖ បាទ។
ខ៖ចា៎។
ក៖
អញ្ចឹងមិត្តភាពរវាងប្តីហើយនិងប្រពន្ធរបស់អ៊ំគឺត្រូវបានបែកចេញពីគ្នានៅក្នុងសមយ័ពុលពតនិ
ង?

ខ៖ ចាំបែកគ្នារហូត។
ក៖ បែករហូត។
ខ៖ ចាំ។
ក៖ រហូតដល់៣ឆ្នាំ៨មួយភែថ្ងៃនិងមែន។
ខ៖ ចាំ បែករហូតព្រោះអីអាដែងគេអោយគាត់ទៅកិនស្រូវហើយខ្ញុំទៅស្ទូងដងនៅហ្មេះ។
ក៖ ទៅស្ទូងដក។
ខ៖ ហើយអ្នកខ្លះត្រូវគេបានវ៉ែសចោលអស់ហើយ។
ក៖ បាទ ។
ខ៖ ម្លោះហើយទាល់តែចូលស្រុកចូលទេសនិងក៏បានជុំគ្នាវិញ។
ក៖ បាទ។
ខ៖
អ៊ំអាចនិយាយអំពីទិដ្ឋភាពពេលគេជំលាសនិងថាតើដោយការស្មើរជើងឬក៏គេជិះឡានជិះអីនិងនៅក្នុងពេលនិង?
ខ៖ អ៊រកាលនិងនៅពេលដែលពួកវាជំលាសនិងវាអោយជិះកាណូត។
ក៖ ជិះកាណូតទៅសិន។
ខ៖ ជិះកាណូតនិងតាមទន្លេនេះទៅ។
ក៖ តាមទន្លេនិងទៅ។
ខ៖ ចាំ ទៅចឹងទៅក៏វាអោយឡើងឡាន។
ក៖ វាអោយឡើងឡាន។
ខ៖
ឡើងឡានទៅក៏វាអោយជិះឡើងឡានទៅក៏វាអោយជិះបានគេនៅពេលទៅដល់កន្លែងពោសាតន៏និងគេគេយកអាទេសគោអាទាសស្មីនិងយកមកដឹកមកចែកតាមភូមិ។
ក៖ បាត។
ខ៖ យកមកចែកតាមភូមិចឹងទៅ។
ក៖ បាទ។
ខ៖
ក្នុងម៉ាស្រុកនិងគេដដាក់ពង្រាយនប៉ុន្មានអ្នកចឹងទៅគេដាក់តែ១០អ្នកនិងទៅ២០អ្នកនិងទេ។
ក៖ បាទ។
ខ៖ គែដាក់ចឹងទៅ។

កៈ
ចុះអ៊ំអាចរៀបរាប់អំពីសំលៀកបំពាក់ពួកអង្គការពុលពតនៅក្នុងសមយ័និងគេគេស្លៀកពាក់អី
គេដែលនិយមពាក់ជាងគេ?
ខៈ ជំនាន់អាពតបានក្រមាសក្រហមហើយនិង។
កៈ ហើយនិងខោអាវអី។
ខៈ ខោអាវខោខ្មៅអាវខ្មៅកាត់សក់ការ៉េ។
កៈ កាត់សក់ការ៉េ។
ខៈ ចាំ ។
កៈ ហើយនិងជាទូទៅអោយតែអ្នក។
ខៈ អានិងដល់តែ។
កៈ អង្គការគេធ្វើចឹងទាំងអស់?
ខៈ ចាំ អានិងគេពិសិសគេហើយនិងអានិង។
កៈ ពិសិសគេ។
ខៈ អានិងខោអាវគេលេខមួយនិងហើយអានិង។
កៈ ខោអាវគេលេខមួយនិងនៅក្នុងសមយ័និង។
ខៈ ចាំ និយាយអោយត្រង់អោយតែមើលគេដឹងថាខោអាវអ្នកដឹកនាំនៅក្នុងសមយ័ពុលពត។
ខៈ ចាំ ។
កៈ
ចុះអ៊ំនៅក្នុងសមយ័ពុលពតអ៊ំរស់អាពេលទៅដល់អាពេលគេជំលាសទៅដល់និងគេបានចែក
ផ្ទះអោយអ៊ំនៅម្នាក់មួយអីអត់?
ខៈ ចាំ គេធ្វើ។
កៈ ម្នាក់មួយៗ?
ខៈគេធ្វើផ្ទះអោយម្នាក់
មួយៗៗនៅជាប់ៗៗៗគ្នា។
កៈ បាទ។
ខៈ ចាំ នៅជាប់គ្នាចឹងនិងណា។
កៈ ខ្ញុំធ្លាប់សំភាសន៏ថាគេថាផ្ទះឈើដែលគេអោយសុទ្ធតែជាផ្ទះឈើល្អៗៗស្អាតៗៗអីនិង។
ខៈ ផ្ទះឈើៗតូចៗៗនិង។
កៈ តូចៗៗទេ។
ខៈ ចាំ រួចទៅអាជញ្ជាំងនិងគឺជាជញ្ជាំងស្លឹកទេ។
កៈ ជញ្ជាំងស្លឹក។

ខ៖ ចាំ គ្រាន់តែឈើនិងគឺជា។
ក៖ ឈើនិងវាល្អ។
ខ៖ ឈើនិងវាឈើនិងវាល្អដែល។
ក៖ បាទ។
ខ៖ គេរូសពីផ្ទះអាធំនិងមកចែកជូនប្រជាជននិងនៅទៅ
ក៖ បាទ។
ខ៖ ចេះតែចែកគ្នានៅតៗៗៗៗៗៗគ្នានិងនៅទៅ។
ក៖ អ៊ំបានបែកពីប្តីចឹងថាតើអ៊ំតើអ៊ំនៅតែម្នាក់ឯងឬក៏នៅជាមួយកូនមួយ។
ខ៖បែលពីប្តីខ្ញុំខ្ញុំនៅជាមួយម៉ែខ្ញុំ។
ក៖ នៅជាមួយម៉ែ។
ខ៖ ចាំនៅជាមួយម៉ែនៅជាមួយម៉ែគង់។
ក៖ ម៉ែគង់។
ក៖ តើអ៊ំមានបានកើតបានកូនមួយនៅក្នុងសមយ័ពុលពតនិងជំនាន់អាពតនិង?
ខ៖ ជំនាន់អាពតកើតបានកូនមួយ។
ក៖ កើតបានកូនមួយ។
ខ៖ ចាំ ។
ក៖ បាទ ចុះនៅក្នុងជំនាន់ពុលពតការងារអីគេខ្លះដែលអ៊ំបានធ្វើនៅក្នុងជំនាន់និង?
ខ៖ ជំនាន់អាពតនិងមានអីមានតែស្ទូង។
ក៖ ស្ទូង។
ខ៖ ចាំ ស្ទូងស្រូវ។
ក៖ ស្ទូងស្រូវធ្វើសំណាប។
ខ៖ ចាំ ស្ទូងស្រូវហើយខ្ញុំរែកទឹកដំណាំ។
ក៖ រែកទឹកដំណាំ។
ខ៖ ចាំ រែលទឹកនិងដូចជាដាំទ្រាំ។
ក៖ ដាំទ្រាំ។
ខ៖ ដូចជាស្ពៃ។
ក៖ បាទអត់មានធ្វើបង្គីរដោយអាដើមអីគេមួយនោះអៅអត់ទេ?
ខ៖ អត់តេអត់ទេអត់មានធ្វើរបង្គីរអីទេ។
ក៖ បាទ។
ខ៖ ចាំ ។

កៈ
អញ្ចឹងទិដ្ឋភាពនយ័កាលកើតនិងថាតើកាលកើតកូននៅសមយ័ពុលពតនិងយ៉ាងម៉ិចដែលអ៊ំ?
ខៈ កាលកើតនៅក្នុងសមយ័ពុលពតនិងម៉ែខ្ញុំគាត់ទៅជាមួយពីដើមគាត់ធ្វើជាយាយឆ្មប។
កៈ ធ្វើយាយឆ្មប។
ខៈ ចាំ. ដល់ពេលនេះកើតនៅផ្ទះ។
កៈ បាទ។
ខៈ ចាំ ហើយដល់ពេលកើតទៅគាត់រកថ្នាំខ្មែរអីអោយហូប។
កៈ បាទតែខ្ញុំអត់បានទៅមណ្ឌលអីទេព្រោះអី។
កៈ បាទ។
ខៈ ម៉ែខ្ញុំគាត់រត់តាមខ្ញុំទៅនិង។
កៈ បាទ។
ខៈ ព្រោះអីខ្ញុំទង្វន់ពីនិងទៅហើយនិង។
កៈ
ចុះប៉ន្មានថ្ងៃដែលនៅពេលដែលបានកើតហើយអាពតបានអោយទៅនៅមើលកូនឫក៏នៅតែអោយធ្វើការធ្ងន់ទៀត?
ខៈ អ៊ររយេះកាលបានប្រហែលជាកូនបាន២ខែ។
កៈ ២ខែរួចហើយយើងទៅ។
ខៈ អោយយើងទៅស្ទូងដក។
កៈ ស្ទូងដក។
ខៈ ចាំ។
កៈ ស្ទូងដកដូចជាកម្មករឬក៏ប្រជាជនសមញ្ញទូរទៅទាំង។
ខៈ និយាយអោយចំទៅជាទូរទៅតែម្តង។
ខៈ ចាំ ។
កៈ សំម្រាប់កាលញាំវិញ។
ខៈ ញ៉ាំ។
កៈ ថាតើញ៉ាំជាសមូលហាភាពឬក៏ជាឯកជន?
ខៈ ញ៉ាំរួម។
កៈ ញ៉ាំរួម។
ខៈ ដូចថាដាក់អីគេនៅក្នុងរោងវ៉ៃប៉ូក១១ចឹងទៅ។
កៈ បាទ។
ខៈ វ៉ៃចឹងទៅហើយក៏យកចានទៅដាក់ទំរាបទៅ។

កះបាទ។
ខះ ចាំ រួចទៅក៏ចែកបបរទៅហើយមួយវែកៗៗទៅ។
កះ អញ្ចឹងអាហារដែលមានតែបបរមួយទេ?
ខះ បើសំម្លរគេមានដៃតំលូង។
កះ មានដៃដំលូង។
ខះ មានត្រីប្រលាក់។
កះ បាទ មានត្រីប្រលាក់។
ខះ មានដើមចេក។
កះ មានដើមចេក។
ខះ ដាក់ស្លរទៅដូចអាយើងដាក់ដូចជាសម្លរជ្រូកចឹងទៅ។
កះ បាទដូចជាសម្លរជ្រូកចឹង។
កះ
ចុះលោកអ៊ំគិតថាអាហាសមយ័និងគ្រប់គ្រាន់សំរាប់ដូចជាផ្តត់ផ្គងសំរាប់សុខភាពអ៊ំអីនិងអាហាពេលនិង?
ខះ អ៊ឺរអោហាពេលនិងគឺមិនគ្រប់គ្រាន់ទេក្មួយអើយ។
កះ មិនគ្រប់គ្រាន់ទេ។
ខះ ចាំ គ្រាន់តែគិតថាមិនហូបម៉ិចកើតទៅយើងគ្រាន់តែហូបអោយតែ។
កះ បាទ។
ខះ អោយតែរស់ៗទៅជួនកាលខ្វះជីវជាតិដល់ពេល។
កះ បាទ។
ខះ ខែនេះទៅហើម។
កះ បាទ។
ខះ
ហើមចឹងទៅយកកន្ទក់និងយកមកអណ្តែងរ៉ែងវាទៅយកមកទៅក៏ដាក់វិចវាចាអន្សបចឹងទៅហូបទៅ។
កះ បាទ។
ខះ ហូបទៅកំអោយវាហើម។
កះ អ៊ឺររ។
ខះ ចាំ ។
កះ អញ្ចឹងអ៊ំដែលឃ្លានមែនទែនរហូតដល់តែទៅញាំស្លឹកឈើអីគែមួយអីអត់។
ខះ អត់ទេខ្ញុំ។

ក៖ អត់ទេ។
ខ៖ ដល់ពេលនេះព្រោះខ្ញុំបានប្ដីខ្ញុំគាត់បានឡើងត្នោត។
ក៖ បាទ។
ខ៖ យកអាត្នោងនិង។
ក៖ យកផ្លែវា។
ខ៖ យកអាចាស់ៗៗៗកាលនិងយើហាយកវាសកជាសំបកហើយយើងបានដាក់ក្នុងកៅសៀរ។
ក៖ បាទ។
ខ៖ ដាក់ក្នុងកំសៀររួចហើយរួចហើយយើងដា។
ក៖ បាទ។
ខ៖
យើងដាំអាពតបានសួរខ្ញុំថាញ៉ាមអីធ្វើអីនិង?ហើយខ្ញុំក៏បានប្រាប់ថាខ្ញុំបានដាំទឹកតែការពិតខ្ញុំបានយើងដាក់អានិង។
ក៖ បាទ។
ខ៖ ចាំ គេដាក់រំងាស់អាត្នោងចឹងទៅ។
ក៖ បាទ។
ខ៖ បើសិន។
ក៖ ដើម្បីយកញាំ។
ខ៖ បើអាពតបានដឹងពេលនិងក៏វារ៉ៃយើងចោលដដែល។
ក៖ បាទ។ចឹងអោយតែ។
ខ៖ អោយតែមានភ្លើងអី។
ក៖
អញ្ចឹងអាពតនិងទ្រឹស្តីវាគឺមិនចង់អោយប្រជាជនមានកំលាំងគ្រប់គ្រាន់នៅពេលបានញាំអីជិតដល់ហើយញាំអីឆ្អែតឬក៏សុចភាពល្អទៅវាខ្លាចឬក៏ជាជនបេះបោល?
ខ៖ វាមិុចអោយយើងហូបគ្រប់គ្រាន់នោះព្រោះអីវារកតែសំលាប់យើងនិង។
ក៖ អ៊ើរ។
ខ៖ វាមានអោយយើងហូបគ្រប់គ្រាន់ទេ។
ក៖ បាទ។
ខ៖ មានទៅខ្វះអីស្រូចអង្ករនិងតែបើវាមិនអោយយើងហូប។
ក៖ បាទ។
ខ៖ រាល់តែថ្ងៃនិងអោយយើងហូបតែបបរមួយស្លាបព្រាចឹងទៅម្លោះហើយ។
ក៖ បាទ។

ខ៖ ហូបទៅវាថាមិត្តយើងហាហូបទៅអាចន៍មកដូចជាអាចន៍ជ្រូកចឹង។
ក៖ បាទ។
ខ៖ បើហូបតែផ្ទីហូបតែបន្លែ។
ក៖ បាទ។
ខ៖ ចំនែកពួកវាវាហូបបាយបានអីវាបានចឹងទៅ។
ក៖ បាទ។
ក៖ ចុះអ៊ំមានដែលលើកទំនប់លើកប្រលាយអីអត់លើកភ្លើរលើកអីនៅក្នុងសម័យនិងអត់?
ខ៖ លើលតា។
ក៖ លើក។
ខ៖ ចា៎ ។
ក៖ លើកអីគេដែល?
ខ៖លើក។
ក៖ លើកទំនប់អីគេដែល ?
ខ៖ កាលជំនាន់និងខ្ញុំវាអត់ដឹងមិនដឹង។
ក៖ លើកភ្លើអីចឹង។
ខ៖ វាមិនដឹងអីមិនដឹងថាភ្លើអីចឹងចេះតែលើកៗៗៗៗទៅកំពស់ចុងដូងកំពស់ចុងស្វាយអីចឹង។
ក៖ អ៊ែរចឹងខ្ពស់ណាស់ចឹងអ៊ំហ្មោះ។
ខ៖ ចា៎
បើសិនជាដើរទៅខុសហៅវាហើយវាថាកំអោយជាន់និងហើយយើងភ្លេចត្រចៀកពេលយើងដើរទៅហៅយើងមកកាប់កាប់និងកាប់ចោលភ្លាមកំអោយគេយកតំរាបតាមអាស្មីគេកកុកនិង។
ក៖ កកុក។
ខ៖ អាកាំនបិទកកុកនិង។
ក៖ កាំបិតកកុកនិងអាក្រងុកចេះនិងអ៊ំ។
ខ៖ ចា៎ និងហើយ។
ខ៖ កាប់ម៉ាត់ទៅកំអោយគេយកធ្វើតំរាប់តាម។
ក៖ អ៊ំធ្លាប់ឃើញនិងភ្នែកទេអ៊ំ?
ខ៖ ចា៎ ខ្ញុំបានឃើញនិងភ្នែក។
ក៖ អញ្ចឹងស្រៀវណាស់អញ្ចឹងអ៊ំហ្មោះ។
ខ៖ ចា៎ ។
ក៖ វាគួរអោយយើងបាក់ស្បាតនិងណា។
ខ៖ វាធ្វើកំអោយវាកំអោយអ្នកនេះធ្វើតំរាប់តាមននិងណា។

កៈ បាទ។

ខៈ ចា៎ ។

កៈ

ចុះសំរាប់ការឈេីតង្កាត់នៅក្នុងសមយ័ពុលពតនិងមានមន្ទីពេទ្រមានគ្រូពេទ្យព្យាបាលជំងឺអី។

ខៈ អត់មានទេ។

កៈ អត់មានទេ។

ខៈ អត់មានទេមានតែគេយកអាថ្នាំខ្មៅដូចជាអាចន៏ទន្សាយអាតូចៗៗៗប៉ុននេះ។

កៈបាទ។

ខៈ អានិងមិនដឹងថាថ្នាំស្វន្សអីវាទេ។

កៈ បាទ។

ខៈ រួចទៅខ្ញុំមិនដែលលេបទេអត់ដែលលេបទេ។

កៈ អត់ដែលលេបអាថ្នាំស្វន្សនិងទេ?

ខៈ អត់ដែលលេបអាថ្នាំនិងទេ។

ខៈ អាថ្នាំស្វន្សនិងមិនដឹងជាថ្នាំអីគេមិនសដឹង។

កៈ មិនដឹងជាថ្នាំអីគេទេបាទ។

ខៈ មិនដឹងជាថ្នាំគ្រុណថ្នាំក្តៅអី។

ខៈ ម្លោះហេីយពេលដែលឈឺទៅចេះតែឈឺទៅ។

កៈ ចុះអ៊ំធ្លាប់មានជំងឺណាដែលអ៊ំឈឺជាងគេនៅក្នុងជំនាន់និងអីអត់ក្នុងសមយ័ពុលពតនិង?

ខៈ ខ្ញុំកាលពីជំនាន់ពុលពតនិងខ្ញុំដូចជាអត់ឈឺទេ។

កៈ អត់ឈឺទេ។

ខៈ ចា៎។

កៈ ដូចអត់មានគ្រុណចាញ់អីគេអ៊ំ?

ខៈ មានតែគុណព្រះចេះតែជួយទៅអត់មានគ្រុណចាញ់អីទេ។

កៈ បាទ។

ខៈ ចា៎

ចុះអ៊ំអាចសង្ខេបដូចជាភាពលំបាកដ៏ខ្លាំងដែលមិនអាចបភ្លេចបានក្នុងសមយ័ពុលពតថាតេីពេលវេលាមួយណាដែលអ៊ំគិតថាពិបាកជាងគេអ៊ំ?

ខៈ អឺរ។

កៈ ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃនិង?

ខៈ អាពិបាកជាងគេពេលអាពតវាអោយយេីងដកស្ទូងនិងម៉ង។

កៈ ដកស្ទូងនិងពិបាកម៉ង។

ខ៖ ចាំ
អោយវាដកស្ទូងនិងអោយតែពេលដែលខ្ញុំទៅដកស្ទូងនិងម្តងៗៗៗតាំងពីចាមតាំងពីស្អីឡើង
ទៅឆ្លើងពាក់ប្រកង់ត្រង់តាំងពីត្រង់និងទៅរហូតដល់និង។
ក៖ បាទ។
ខ៖
ម្លោះហើយកាលណាយើងស្ទូងមិនទាន់គេវាដករបបយើងអីស៊ីម្លោះហើយយើងខ្ញុំខំប្រឹងភ្លេច
ភ្នែកខំប្រឹងឈ្លើងតោងអីតោងទៅ។
ក៖ បាទ។
ខ៖ ចាំ ។
ក៖ អត់ខ្វល់?
ខ៖ ចាំ អត់ខ្វល់អត់ខ្វល់ទេដល់តែពេលឃ្លេរទៅវាស៊ីឈាមយើងឆ្អែតទៅវាក៏ជ្រុះខ្លួនឯងទៅ។
ក៖ បាទ។
ខ៖ គ្រាន់តែនៅពេលដែលស្ទូងនិងយើងនៅតែខ្លាចនិង។
ក៖ បាទ។
ខ៖ យើងធ្វើមិនទាន់គេវាដករបបនិងក្នុងម៉ារ៉ែកនិងវាទុកអោយមួយស្លាបព្រាបាអីហូប។
ក៖ បាទ។
គេមានកំនត់ថាអោយយើងត្រូវស្ទូងប៉ុន្មានកណ្តាប់ក្នុងមួយថ្ងៃអីនិងទេ?
ខ៖ អត់មានអត់មានដាក់កំរិតទេ។
ក៖ អត់មានដាក់កំរិតទេ។
ខ៖ ចាំ អត់មានដាក់កំរិតទេអោយតែយើងស្ទូងទាន់គេទាន់ឯង។
ក៖ បាទ។
ខ៖ ចាំ ។
ក៖ ចុះពេលវេលាញ៉ាំបាយវិញតើមានប៉ុន្មានពេលក្នុងមួយថ្ងៃនិង?
ខ៖ អឺរអាពេលបាយនិងត្រឹមម៉ោង១០អីទៅគេវ៉ៃជួងហើយហើយក៏ទៅៗៗ។
ក៖ បាទ។
ខ៖ ដល់ម៉ោងប្រាំល្ងាចទៅគ្រាន់ទៅដាក់លីប៉ូកៗៗយកចានដាក់ទំរាបទៅ។
ក៖ អញ្ចឹងមាន២ពេលក្នុងមួយថ្ងៃ។
ខ៖ មានតែ២ពេលទេអត់មានបានច្រើនពេលនិងគេទេ។
ក៖ បាទ បាទ។

កៈ
ប៉ុន្តែប៉ុន្តែពីពេលនិងសឹងតែពីពេលដូចជាបាយជ្រូកតែពេលខ្លះអត់ដូចជាបាយជ្រូកទេព្រោះអីវាតិចមែនទែន។
ខៈ វាតិចណាស់បើចំនីជ្រូកវិញវាគ្រាន់ជាឆ្ងាញ់ជាង។
កៈ បាទ។
ខៈ ចំនែកឯអាជំនាន់អាពតវិញគ្មានអី។
កៈ ចប់ម៉ងអាំហ្នោះ។
ខៈ គ្មានអីឆ្ងាញ់ទេ។
កៈ បាទ។
កៈ យើងទៅយកបានតែមួយដងយើងអត់អាចថែមទៀតអីបានទេ។
ខៈ
បើយើងអត់ទេដូចជាយើងបានបបរបានតែមួយស្លាបព្រារចឹងទៅយើងអាចយកដៃតំលូងឬមួយយើងអានោងចឹងទៅពេលយើងយកមកចឹងយើងយកមកស្ងោចឹទៅដូចជាធ្វើរទឹកត្រីចឹងទៅទឹកត្នោតនិងធ្វើជាទឹកត្រីទៅជ្រលក់ទៅគ្រាន់តែបានបំពេញពោះទៅរួចគ្រាន់តែអាបបរមួយស្លាបព្រារនិងយើងគុពន់តែហូបមិុចគ្រាន់។
កៈ បាទ។
ខៈ ហើយរួចដល់ពេលអាខែវាលុតជំឡើងហើមម្នាក់ៗៗៗហើមស្ដីងៗៗៗ។
កៈ បាទ។
កៈ
ចុះសំរាប់ម្ដាយអុំវិញតើគាត់នៅក្នុងសម័យនិងតើពេលគាត់នៅជាមួយអុំចឹងថាតើអុំថាគាត់ត្រូវបានជាគេត្រូវគេធ្វើបាបអីអត់ឬក៏គេអោយគាត់ធ្វើអីធ្ងន់ៗៗៗអីអត់?
ខៈ ម្ដាយខ្ញុំដែលគេអោយនៅជាមួយខ្ញុំគេអោយគាត់នៅមើលថៅ។
កៈ គេអោយនៅមើលថៅ។
ខៈ មើលថៅៗៗនិងជាកូនខ្ញុំនិងណា។
កៈ បាទ។
ខៈ រួចទៅពេលនេះពេលគាត់ហើមចេះតែហើមស្រកហើមស្រកចឹងទៅ។
កៈ បាទ។
ខៈ
ហើយទៅប្ដីខ្ញុំគាត់ទៅយកអាកន្ទក់និងមកយកវារ៉ែងអោយម៉ត់ទៅហើយយើងយកវាមកជលកទៅដាក់ជាស្ករជាអីចឹងទៅហើយត្នោតអីនិងទៅដាក់វាវិចជាអន្សមហូបទៅ។
កៈ បាទ។

ខ៖ គ្រាន់និងបានជាតិផ្អែម។
ក៖ អញ្ចឹងគាត់ដូចកាងាររបស់គាត់គឺមើលចៅ។
ខ៖ គាត់នៅមើលចៅ។
ក៖ គាត់ដូចជាអត់មានឧកាសបានចូលរួមធ្វើជាចុងភៅអីអត់?
ខ៖ អត់ទេអត់ទេអត់បានធ្វើចុងភៅអីទេព្រោះអីគាត់ចាស់ណាស់។
ក៖ បាទ។
ខ៖ គាត់ចាស់ហើយចចឹង។
ក៖ អ៊ំរគាត់ចាស់ហើយ។
ខ៖ ចាស់ហើយ។
ក៖
ខ្ញុំដូចជាធ្លាប់បានលឺថាពេលខ្ញុំសំភាសន៍គេថាអ្នកដែលរាងចាស់ៗគេអោយនៅនឮមើលកូនចៅ។
ខ៖ អោយនៅមើលកូន។
ក៖ បាទ។
ខ៖ ចាំ ។
ក៖ ហើយអ្នកណាអាចមានកំលាំងបានហើយធ្វើម្ហូឆ្ងាញ់បានធ្វើចុងភៅ។
ខ៖
ចុងភៅនិងទាល់តែមានដូចជាទាល់តែគេមានខ្នងអីទាល់តែពួកគេមានខ្នងអីទើបគេអចធ្វើជាចុងភៅបានកន្លែងដែលគេដាក់ចុងភៅគឺជាកន្លែងរស់និងណា។
ក៖ បាទ។
ខ៖ ចាំ បើយើងអត់មានខ្នងអត់មានអី។
ក៖ គេងត់ដាក់ចូលទេ។
ខ៖ គេអត់អោយយើងដដាក់ចូលទេ។
ក៖ បាទ។
ខ៖ មិនអាចហើយយើងទៅទេគឺមិនអាច។
ក៖ បាទ។
ខ៖ អោយដើរតាមសមរភូមិហើយ។

ក៖ បាទ។
ក៖
ចុះអ៊ំនិយាយអំពីការកាប់សំលាប់វិញថារឿងមួយនិងគឺជាអ្វីដែលមនុស្សជំនាន់ក្រោយចង់ដឹង

អំពីឃាតកម្មនិងអំពីភាពព្រៃផ្សៃនៅក្នុងងេះនាន់និងអ៊ំមានដែលឃើញនិងភ្នែកអំពីទន្ទកម្មសព្វគ្រប់បែបយ៉ាងនៅសមយ័និងទេអ៊ំ?
ខ៖ ចា៎ ។
ក៖ ទន្ទកម្មដែលមាននៅសមយ៏ពុលពតនិងអ្នកមីងមានអីគេខ្លះ?
ខ៖
នៅក្នុងសមយ័និងថាដល់ពេលនេះវាថាអោយយើងទៅស៊ីបាយអោយទៅស៊ីបាយចឹងទៅវាថាពួកបងប្អូនស្វាយរៀងនិងណា។
ក៖ បាទ។
ខ៖ បើមិនខំយួនចូលហើយហា
យែនាំយើងទៅស៊ីបាយរួចហើយទៅស៊ីបាយទៅធ្វើការធ្វើអីទៅមួយកងអាទេះម៉ាកងអាទេះទៅអាមានខោវាមួយចំហើងចេះហើយមានមួយចំហៀងទំលាក់ដើម្បីអោយគេដឹងថាអាមួយគ្នាវាអាមួយគ្នាគេនិងណា។
ក៖ បាទ។
ខ៖ពេលទៅដល់អាកាំបិទកក្រង៉ុកនិងនោះចូលទៅវាប្រលូកកាប់ៗៗៗៗៗងាប់អស់។
ក៖ បាទ អ្វីដែលអ៊ំនិយាយនិងអ៊ំបានមើលឃើញនិងភ្នែកផ្ទាល់?
ខ៖ ចា៎ ខ្ញុំបានមើលឃើញនិងភ្នែក។
ក៖ ឬក៏អ្នកនៅក្បែរៗៗៗៗនិងគេចេះតែប្រាប់ទៅអ៊ំក៏ថាតាមគេ។
ខ៖ កំពុងតែពេលស្ទូងស្រូវអីចឹងទៅក៏គេ។
ក៖ បាទ។
ខ៖
តើឯងមកពីណាក៏ថាម៉ែខ្ញុំគឺមកពីទីនោះវាមិនអោយជួបបងប្អូនអាដែងបងប្អូនស្វាយរៀងអាដែងថាចូលមកត្រូវអាដែងវាចូលខាងយួនហើយ។
ក៖ បាទ។
ខ៖ សូម្បីតែក្មេងកំពស់នេះយកមកកាត់ម៉ាត់ងាប់។
ក៖ សាហាវណាស់អ៊ំហ្មោះ។
ខ៖ ចា៎ អាកាំបិទកកុងនិង។
ក៖
អញ្ចឹងអ៊ំបានឃើញរបៀបនៃការសំលាប់និងនៅក្នុងសមយ័ពុលពតនិងតាមរយះការកាប់ជាមួយនិងអាកាំបីទ។
ខ៖ កាំបិទកកុក។
ក៖និងកាំបិទកកុក។

ខ៖ ចាំ។
ក៖ ចុះមានអីផ្សេងទៀតអត់ដែលអ៊ំធ្លាប់បានឃើញ?
ខ៖ អានិងអ៊ំធ្លាប់និងភ្នែកតែអាកាំបិទកកុកនិង។
ក៖ តែអានិងមួយទេ។
ខ៖ ចាំ។
ក៖
ប៉ុន្តែបើលិចលឺតាមអ្នកផ្សេងអំពីការកាប់សំលាប់និងមានវិធីសាសអីផ្សេងទៀតទេក្រៅពីនិងដូចជាយកដងចបមកវ៉ៃពីក្រោយអីឬក៏ចងស្លាបសេកអីនិង?
ខ៖ តែអានិងខ្ញុំអត់ដែលបានឃើញនិងភ្នែកទេ។
ក៖ បាទ។
ខ៖ ខ្ញុំបានឃើញតតែអាកាំបិទកកុកនិង។
ក៖ បាទ។
ខ៖ ចាំ
ព្រោះខ្ញុំកំពុងតែស្ទូងស្រូវនិងណាវាហៅមកនិងវាកាប់ម៉ាត់ៗៗៗកាប់នៅខាងមុខនិងទៅពេលដែលងាប់ចឹងទៅកេអាចំបើងនិងគរ។
ក៖ គេយកអាចំបើងនិងគរហើយដុតចោលតែម្តង?
ខ៖ ដាក់គរចឹងទៅហើយអាដែងដាក់ពីលើចឹងទៅវាអត់ដុតទេ។
ក៖ អញ្ចឹងវាអត់ស្អុយទេ?
ខ៖ ស្អុយៗៗទៅវាស្រែនិង។
ក៖ វាស្រែហ្មោះអ៊ំ។
ខ៖ ចាំ។
ខ៖ យកទៅសំលាប់ចោលវាស្រែនិង។
ក៖ ចុះអ៊ំមានដែលមានដែលលឺគេនិយាយអំពីការសំលាប់តាមរយះចងស្លាបសេកវ៉ៃអី?
ខ៖ អាណុងចងលរថាខុសសិលធម៌ខុសអីនិងអានិងគេចងគេវ៉ៃចឹងហើយ។
ក៖  បាទ។
ខ៖ចាំ ។
ក៖ អានិងពិតជាលិចលឺធ្លាប់លឺគេនិយាយ។
ខ៖ ចាំ ។
ក៖ និយាយចឹងមែនលោកយាយ?
ខ៖ ចាំនិងហើយព្រោះដូចថាអ្នកស្រលាញ់គ្នាអីខុសសិលធម័អីចឹងទៅ។
ក៖ បាទ។

ខ៖ ថាអង្គការអោយរៀបហើយតែអត់យកវាទៅយកឯហ្មេះឯហ្មោះអីចឹងវា។
ក៖ បាទ។
ខ៖ ចឹងទៅអាហ្នឹងត្រូវគេសំលាប់ចោលចឹងហើយ។
ក៖ បាទ។
ខ៖ ចា៎ ។
ក៖ ចឹងគេយកទៅសំលាប់ចោលចឹងទៅ។
ខ៖ ចា៎ ។
ក៖ុះ
ហើយពេលហ្នឹងថាតើអ៊ំជិវិតអ៊ំថាតើជិវិតអ៊ំកាលរស់នៅសម័យនិងថាតើវាដូចម៉េចទេថាជិវិតបែបនិងចឹងថាតើវាសប្បាយឬក៏យ៉ាងម៉ិចដែល?
ខ៖
អីរក្សយអើយសប្បាយអីបណ៎អោយតែគឺថាបណ៎គុណព្រះពុទ្ធព្រះសង្ឃអោយជួយគឺបណ៎អោយតែថាអោយតែដល់តែពេលយ៉ាងម៉ិចអោយតែអាពតវាបានរលាយបានចូលស្រុកចូលទេស។
ក៖ បាទ។
ក៖
អីរខ្ញុំភ្លេចនិយាយរឿងមួយថាតើថាសាសនានៅសម័យនិងនៅតែមានដែលអត់ដូចជាមមានវត្តអារាមណ៍លោកសង្ឃអីអត់?
ខ៖ អត់មានទេ។
ក៖ អត់មានទាល់តែសោះ?
ខ៖ ចា៎ ។
ក៖ អត់មានទេ។
ខ៖ ព្រោះគេរំលាយអស់ហើយ។
ក៖ ពុលពតគាត់ជាខ្មែរមែនទេអ៊ំ?
ខ៖
ពុលពតនិងដូចអាមួយនោះនិងចឹងក្មេងនិងអាយុដូចជាដប់ឆ្នាំអីនិងពីដណ្តប់ឆ្នាំអីនិងគ្រាន់តែខ្លាំងខ្លាណាស់អានិងយាយពីសាហាវម៉ងជាក្មេងឈាមរាវ។
ក៖ តែវាអត់សំរាប់ពួកពុលពតវាអត់ជឿទៅលើព្រះពុទ្ធសាសនាទេ?
ខ៖
អានិងវាមានជឿអីបើអត់មានវត្តអីផងរំលាយចោលព្រះសង្ឃអីចាប់សំលាប់អស់ហើយមានអីត្រូវធ្វើបុណ្យ។

ខ៖
អញ្ចឹងមានគេចាត់យើងទៅកន្លែងណាអីផ្សេងអីអត់ឬមួយក៏អោយយើងនៅកន្លែងមួយនៅជាប់រហូត?
ខ៖ នៅកន្លែងណាគឺនៅកន្លែងនិង។
ក៖អត់មានឱកាសបានដើរ?
ខ៖ ត់មានឱកាសដើរហើរហោះហើរទៅណាកើតទេ។
ខ៖ ចឹងដូចជានៅក្នុងគុកមួយហើយចឹង។
ខ៖
អត់មានបានដើរដូចឥលូវនៅក្នុងស្រុកនេះនៅកោះដាច់គឺបាននៅតែនៅកោះដាច់និងបើយើងចេញដើរទៀតអត់មានសំបុត្រស្នាមដែលអាពតធ្វើអោយអត់មានចឹងអាពតវាចាប់ដាក់នៅឯកន្លែងទីរអប់រំនិងគុកនិង។
ក៖ បាទ ដែលមានឱកាសបានឃើញទិដ្ធភាពទីរក្រុងភ្នំពេញនៅក្នុងសមយ៍និងអត់?
ខ៖ អត់។
ក៖ អត់ទេ។
ខ៖ ចា៎ ។
ក៖ អត់មានឱកាសទេ។
ខ៖ ចា៎ ។
ក៖
សំនួរមួយទៀតខ្ញុំចង់សួរអ៊ំថាតើអ៊ំដូចជាធ្លាប់ដូចជាធ្លាប់រើសៗៗៗៗនិងត្រូវយកទៅទេយកទៅសំលាប់ចោលទេ?
ខ៖អ៊ើរ ខ្ញុំរើសដែល។
ក៖រើសដែល ។
ខ៖ ព្រោះប្តីខ្ញុំគាត់រត់ចូលយួន។
ក៖ អ៊ើរ។
ខ៖ ដល់ពេលចឹគេថាអាអ្នករត់ចូលយួនទាំងប៉ុន្មាននិង។
ក៖ ប្រពន្ធអីនិង។
ខ៖ នៅប្រពន្ធនិងតែដល់ពេលអាដែងពេលដែលខ្មែរយើងទៅរំដោះបានក៏បានរួចខ្លួនទៅ។
ក៖ បាទ។
ខ៖ ចា៎ កំអីពេលក៏ត្រូវងាប់ដែលនិងណា។
ក៖ បាទ។
ខ៖ ចា៎ ព្រោះអីគេចងអាអ្នកប្តីរត់ចូលយួននិងចងមួយខ្សែរមួយខ្សែរទៅមុនមុនហើយ។

កៈ បាទ។
ខៈ ខ្ញុំថាអញហើយអញនៅតែថ្ងៃទេ។
កៈ បាទ។
ខៈ
តែដល់ពេលចឹងទៅស្រុកទេសពរព្រើសពព្រុះទៅក៏ពួកយួនពួកអីនិងបានទៅរំដោះបានចឹងទៅ
។
កៈ បាទ។
ខៈ ក៏បានរួចខ្លួយនមក។
កៈ ក៏បានរួចខ្លួនមក។
ខៈ រួចខ្លួនវិញបានចាំ។
កៈ ចុះខ្ញុំចង់បកមកក្រោយវិញបន្តិចតើនិងខ្ញុំអត់សួរជាដឹងទេខ្ញុំនិងណា។
ខៈ ចាំ ។
កៈ ខ្ញុំចង់សួរអ៊ំទុកជាចំនេះដឹង។
ខៈ ចាំ។
កៈ
ថាតើខ្ញុំចង់សួរអ៊ំថាតើសម្ដេចព្រះសីហានុនៅក្នុងសមយ័និងគាត់នៅឯណាថាតើគាត់គង់នៅក
ន្លែងណាដែល។
ខៈ
កាលនិងគាត់និងខ្ញុំមិននេះដែលដូចថានៅក្នុងជំនាន់នុនណុលនិងគាត់ថាកូនអើយមកកូនយើ
ងទៅអណ្ដែងទៅឪទៅជាមួយឪជាមួយឪរួចដល់តែពេលដល់ពេលទៅជាមួយឪចេះតែពេល
ទៅៗៗៗហើយគេថាអាអ្នកយើងនិងគេថាយើងនិងហើយពេលទៅដល់វាបាញ់ចោលៗៗ
បាញ់អស់ទៅ។
កៈ បាទ។
ខៈ ចាំ
មានបានតៅសម្ដេចណាវាបាញ់ចោលអស់ហើយសម្ដេចនិងគាត់ចេះតែស្រែកនៅឯប៉េកកាំង
និង។
កៈ អ៊ូរគាត់នៅប៉េកកាំង។
ខៈ ចាំ ។
កៈ គាត់អត់បាននៅស្រុកខ្មែរទេ?

ខ៖ចាំ
គាត់បាននៅស្រុកខ្មែរទេស្រែកចឹងទៅទៅព្រៃម៉ាក់គីទៅព្រៃម៉ាក់គីចឹងទៅម៉ាក់គីនិងមិនដឹងម៉ាក់គីនៅឯណាទេ។
ក៖ បាទចឹងបាននយ័ថានៅក្នុងសមយ័ពុលពតនិងសម្តេចឪគាត់អត់បាននៅក្នុងទឹកដីខ្មែរទេ។
ខ៖ គាត់មិនបាននៅពីណាគាត់នៅឯប៉េកកាំងឯហ្នោះនិង។
ក៖ មួយទៀតដែលខ្ញុំបានលិចលឺថាពុលពតគឺវាស្អប់មនុស្សចេះដឹងតើវាពិតចឹងមែនអត់?
ខ៖ ចាំ ពិតមែនមើលកាលបងខ្ញុំគាត់អ៊រនៅព្រែកអញ្ចាញ។
ក៖ បាទ។
ខ៖
ស្រុកជីដូនមួយអ៊ំខ្ញុំពីដើមគាត់គាត់បានប្រឹងប្រែងអោយកូនគាត់រៀនរហូតដល់កូនគាត់បានចេះបើកកប៉ាល់ហោះ។
ក៖ បាទ។
ខ៖ ចាំ និងហើយសក័២កប៉ាល់ហោះនិងណា។
ក៖ បាទ។
ខ៖
រួចដល់ពេលចឹងទៅដល់ពេលចូលពេលស្រុកអត់មិនហ៊ានចូលស្រុកទេព្រោះខ្លាចអាពតយកទៅសំលាប់។
ក៖ បាទ។
ខ៖ ស្រាប់ពេលទៅដល់ស្រុកកណ្តៀង។
ក៖ បាទ។
ខ៖
និងវាថាអាពតវាថាមិត្តយើងប្តីធ្វើអីអត់ដឹងថានិងគេយកទៅសំលាប់និងប្តីសក័២បើកកាប៉ាល់ហោះដូចនិងមិត្តយើងសំមិត្តទៅជួយបង្រៀនបើកកាប៉ាល់ហោះពីបីថ្ងៃ។
ក៖ បាទ។
ខ៖
ពីបីថ្ងៃនិងចេះតែចាំបាត់ចឹងទៅក៏ទាល់តែស្លាប់រហូតដល់ពេលបែកភ្នំពេញនិងបានដឹងតើ។
ក៖ បាទ។
ក៖ អញ្ចឹងអោយតែអ្នកចេះដឹងគេសំលាប់។
ខ៖ ចាំ អោយតែចេះដឹងឯគេសំលាប់ចោលអស់ហើយ។
ក៖ ខ្ញុំធ្លាប់បានចូលទៅក្នុងគុកព្រៃទួរស្លែងអីនិងនៅក្នុងឆ្នាំ១៩៧៦។
ខ៖ ចាំ។

កៈ
មានស្លាបនិកពីរូបជាអ្នកបើកយន្តហោះអ្នកដែលចេះផលិតយន្តហោះជាជនជាតិខ្មែរនៅប្រទេសបារាំងត្រូវបាន។
ខៈ ខ្ញុំមានបងបអូនជីដូនមួយពីអ្នកចេះបើកយន្តហោះអាមួយសក័មួយអាមួយទៀតសក័ពី។
កៈ បាទ។
ខៈ គេសំលាប់ចោលអស់ហើយ។
កៈ បាទ។
ខៈ ពីអ្នកនិងបានធ្វើរួមគ្នាក្នុងកាលបង្កើតយន្តហោះនៅក្នុងប្រទេសបារាំងនិង។
ខៈ ចាំ ។
កៈ នៅក្នុងឆ្នាំ៧៦ពុលពតបានស្នើរសំដើម្បីនាំយកពីអ្នកនិងមកខ្មែរ។
ខៈ ចាំ។
កៈ
ពីរអ្នកនិងពិតជាបានមកប្រទេសខ្មែរនៅឆ្នាំ១៩៧៦ពិតមែន៧៧ប៉ុន្តែត្រូវបានបាត់ខ្លួនអញ្ចឹងមួយរយភាគរយត្រូវពុលពតបានសំលាប់ហើយមើលទៅ។
ខៈ ចាំ។
កៈ
អញ្ចឹងនៅពេលដែលចឹងវិញខ្ញុំចង់និយាយអំពីទិដ្ឋភាពនៅថាតើស្ថានភាពនៅពេលសមយ័និងមានភ្លើងអគ្គីសនីយ៍ឬក៏បានប្រើប្រាសចង្កៀងអីអ្នកអ៊ំ?
ខៈ អត់មានអីទេក្មួយអើយដុតអុស។
កៈ អត់មានទេដុតអុស។
កៈ មានទានមានអំពូលម៉ាំសសុងអីអត់?
ខៈ អត់មានអីទេ។
កៈ អត់មានទេ។
ខៈ
តែគ្រាន់តែពេលដែលយើងចង់ភ្លឺយើងទៅធ្វើជាចង្ក្រានដែកដាក់ជីនិងទៅយើងយកអុសដាក់មកគរទៅ។
កៈ បាទ។
ខៈ អត់មានអុសបើមានតែអុសទេក៏អត់មានព្រេងកាតទានអីអុតទេ។
កៈ
ចុះអ៊ំសាំប់សិស្សក្មេងៗៗទូចៗៗនៅក្នុងសមយ័និងដែលនៅអាយុប្រាំមួយឆ្នាំប្រាំពីរឆ្នាំនៅក្នុងសយ័ពុលពតនិងមានឧកាសបានទៅរៀនសូត្រអីនិងគេដែលអត់អ៊ំ?

ខ៖ អ៊ នៅក្នុងជំនាន់និងអត់មានឃើញទៅរៀនទៅអីផងអត់ទេ។
ក៖ អត់បានទៅរៀនទេ។
ខ៖ ចាំ
អត់បានទៅរៀនទេអត់បានទៅរៀនតែគិតតែច្រៀងអីគេអាបទស្អីគេនោះច្រៀងតែចឹង។
ក៖ បាទ។
ក៖
ក្មេងអាយុប៉ុន្មានដែលដែលពុលពតប្រើអោយទៅធ្វើកាមិនមែនជាការងាធ្ងន់តែអាចជាការងារប្រចាំថ្ងៃ?
ខ៖ អីទេកាលពីជំនាន់ពុលពតនិងអាក្មេងៗៗនិងខ្ញុំដូចជាអត់ដឹងដែលទេ។
ក៖ អត់ដឹងសោះម៉ង។
ខ៖ ចាំខ្ញុំអត់ដឹងសោះម៉ងខ្ញុំអត់ដឹងទេ។
ក៖ អត់ដឹងទេ។
ខ៖ ខ្ញុំដឹងតែពេលដែលខ្ញុំស្ទូងដក។
ក៖ បាទ។
ក៖ អ៊ំដែលគិតថានៅក្នុងរយះពេលដែល។
ខ៖ ពេលអាពតយកមកអាពតអត់អោយនៅជាមួយម៉ែឪអត់អោយ។
ក៖ បាទ។
ខ៖ ប្រមូលទៅតាមកន្លែងរបស់វា។
ក៖ ប្រមូលទៅតាមមណ្ឌលកុមារផ្សេងៗៗៗ។
ខ៖ ព្រោះថាគេមានមនុស្សគេមើលហើយនិងណា។
ក៖ បាទ។
ខ៖ ចាំ ។
ក៖
ចុះអ៊ំពាក្រពេចន៍អីគេខ្លះដែលអ៊ំគិតថាមិនដែល្លេចសោះឡើយមកដល់ឥលូវនិងពាក្រពេចន៍ដែលពួកពុលពតឬក៏ពាក្រពួកមេកងពួកពុលពតចូលចិត្តប្រើជាងគេនៅក្នុងសម័យនិងពាក្រអីគេខ្លះដែលអ៊ំគិតថាមិនដែលភ្លេចអំពីជំនាន់និង?
ខ៖ ជំនាន់និងអាជំនាន់ពុលពតនិងខ្ញុំសូមកុំអោយកើតទៀតខ្ញុំវេទនាណាស់។
ក៖ វេទនាណាស់។
ក៖
ចុះពាក្រពុលពតចូលចិត្តនិយាយដូចជាពាក្រថាសក្តិភូមិមិត្តយើងអីនិងមានពាក្រអីណាផ្សេងអីទៀតអត់មានអីដែលអ៊ំបានចងចាំអីទេអ៊ំ?

ខ៖ ចាំហ្នឹងហើយមានពាក្រមិត្តយើង។
ក៖ សក្តិភូមិ។
ខ៖ ហ្នឹងហើយនិយាយតែពាក្រថាមិត្តយើងៗៗៗ។
ក៖ និយាយតែពាក្រមិត្តយើងៗៗៗ។
ខ៖ ចាំ។
ក៖ ហើយគេតែងតែពិពរណ៍នាខ្លួនគេទៅជាអង្គការ។
ខ៖ចាំ
ក៖
គេនិយាយដូចជាគេអត់និយាយដូចជាខ្ញុំតែគេអត់ប្រើទេគេប្រើពាក្រថាអង្គការចឹងមែនអត់?
ខ៖ អង្គការមិត្តយើង។
ក៖ អង្គការមិត្តយើង។
ខ៖ អង្គការមិត្តយើងស្ទើរសំអីចឹង។
ក៖
អ៊ំដែលលឺអាពាក្រទ្រឹស្តីបទមួយដែលពេញនិយមជាងគេនៅក្នុងសម័យនិងពួកពតតែងតែនិយាយថាដកចេញក៏មិនខាតអីគេនិងដែលលឺអត់?
ខ៖អានិងមែន?
ក៖ បាទ។
ខ៖ នៅក្នុងជំនាន់និង។
ក៖ ទុកក៏មិនចំនេញដកចេញក៏មិនខាត។
ខ៖ ពួកអាមេកងគេថាដកចេញអ៊ីរទុកក៏មិនចំនេញដកចេញក៏មិនខាត។
ក៖ បាទ។
ខ៖ ចាំ។
ក៖ ធ្លាប់លឺមែនអត់អ៊ំ?
ខ៖ ចាំ ពួកអាពតនិយាយតែចឹងអានិងធ្វើការខុសវានិយាយចឹងនៅពីមុខយើង។
ក៖ ដែលមនាឧកាសបានជួបមុខពលពតនៅក្នុងសម័យនិងអត់?
ខ៖ អ៊ីរ។
ក៖ សាឡុតស?
ខ៖ ជួបតើអាពួកមេកងវាអីគេនិងដូចថាពេលខ្ញុំទៅនិងឈ្មោះមេកងតាប៉ាន។
ក៖ តាប៉ាន។
ខ៖តាប៉ាននិងគឺសហាវណាស់។
ក៖ សាហាវនិង។

ខ៖ ចាំ
បើសិនជាថាយើងឃើញឃើញថាយើងមានអីដូរដោះអីនិងវាយកយើងទៅសំលាប់ចោល។
ក៖ បាទ។
ខ៖ ចាំ នៅពោសាធន៍និងណា។
ក៖ បាទ ។
ខ៖ ចាំ។
ក៖ មេកងនីមួយៗ១២ត្រូវបានរើសឡើងតាមរយៈអីដែលអ៊ំ?
ខ៖ មិនដឹងវាឡើងតាមអីតែគ្រាន់តែពេលដែលជិតបែកពេញយើងនិងយួរៗៗទៅបាត់មួយ។
ក៖ បាទ់មួយ។
ខ៖ ចាំ យួៗៗបាត់មួយ។
ក៖ បាទ។
ខ៖ ចាំ
បាត់មួយតែពេលឈ្មោះយាយម៉ែៗៗកាលនៅនិងយាយថាយាយរស់ៗៗយាយឯងតិចទៀតជិតបានទៅស្រុកវិញហើយ។
ក៖ បាទ។
ខ៖
ខ្ញុំថាគុណព្រះពុទ្ធគុណព្រះធម៍ព្រះសង្ឃអោយបានអោយអាពតវារលាយទៅអោយខ្ញុំបានចូលក្នុងស្រុកវិញព្រោះពះដល់ពេលយួឬៗទៅដឹងមកពីណាណែយួរៗៗទៅចាប់អាមេកងមួយនិងចេញទៅ។
ក៖ បាទ។
ខ៖ ចាប់យួរចេញទៅរួចហើយក៏បានទៅរំដោះបានពួកខ្ញុំចេញទៅឬំដោះបាន។
ក៖ បាទ។
ខ៖ បើមិនចឹងទេបើមិនយកវាចេញទេមានតែវាធ្វើចិត្តខ្លាំងជាមួនិងយើង។
ក៖ បាទ។
ខ៖ ទោះយ៉ាងណាក៏ដោយក៏ប្រើយើងទៅស្ទូងទៅដកដែលទៅស្ទូងដកដែល។
ក៖ ស្ទូងដកដែល។
ខ៖ ចាំ
ចុះអ៊ំខ្ញុំចង់សួរបកមកក្រោយបន្តិចនៅពេលដែលជំលាសប្រជាជនមួយប្រទេសនិងពុលពតបានប្រើការឃោសនាដូចម្ដេចដែលនៅពេលដែលចាប់ផ្ដើមជំលាសនិងណាអ៊ំ?
ខ៖ អឺរវាជំលាសនិងវាថាមិត្តយើងទៅអោយទៅហូបបាយ។
ក៖ ទៅហូបបាយ។

ខ៖ ចាំ។
ក៖ វាអត់មានថាប្រទេសណាដូចជាអាមេរិចមកវាយមកធ្វើបាបមក?
ខ៖ អត់ទេ។
ក៖ មកទំលាក់គ្រាប់បែកអី។
ខ៖ អត់ទេ។
ក៖ យោសនាចឹង។
ខ៖ អាពេលដែលខ្ញុំស្ទូងស្រូវចឹងទៅស្ទុងទៅទៀតស្ទូងទៅ។
ក៖ បាទ។
ខ៖ និងហើយអីរប្រយត្ត័យួនចូលមក។
ក៖អីរវាគ្រានើតែនិយាយថាខ្លាចយួនដ៩តែមួយគត់វាថា។
ខ៖ វាថាចូលទៅប្រយត័យួនយកទៅហើយយើងបានអីគេស៊ីយកអង្ករស្រូវយកទៅលាក់។
ក៖ បាទ។
ខ៖
រួចចេះតែយកអាដែងចេះតែទូរស្រូវតែមួយមុខគត់អាស្រូវចក្រហួង១១អាស្រូវដែលធ្វើអោយខ្ញុំខូចក្បាលរហូតមកដល់សព្វថ្ងៃនិង។
ក៖ បាទ។
ខ៖ អាការ៉ុងក្រហាមបីតៅយើងនិង។
ក៖ បាទ។
ខ៖ទូរទៅ។
ក៖ បាទ។
ខ៖ ចេះតែទូរ១១ទៅតាមវាទៅវាអត់អោយយើងទំលាក់ទេ។
ក៖ បាទ។
ខ៖ ចាំ ។
ក៖
អ៊ំមានដូចជាអាដូចជាបានឃើញសក្មភាពសប្បាយរីករាយនៅក្នុងសមយ័និងអត់សមយ័ពុលពតនិងទេ?
ខ៖ អត់មានទេអត់ដែលបានឃើញពេលដែលសប្បាយទេឃើញតែទុក្ខឃើញតែទោស។
ក៖ដែលមានកម្មវិធីអីដែលដូចជាអាហារលាចុងក្រោយគេនៅក្នុងសមយ័និង?
ខ៖ អត់មានអត់មានអាហាអត់មានស្អីជារបស់ឆ្ងាញ់អត់មាន។

កៈ
ដូចជាខ្ញុំធ្លាប់សំភាសន៍គេថាមានថ្ងៃណាមួយពលពតធ្វើជានំបាញ់ចុកធ្វើអីប៉ុន្តែគេបានធ្វើជប់លាងដើម្បីអ្នកដេលគេនិងយកទៅសំលាប់ចោលនិង?
ខៈ អ៊ើរអាជំនាន់និងអាជំនាន់នំបាញ់ចុកនិងអាកាលខ្ញុំទៅដំបូងៗៗៗចវាអោយស៊ីឆ្អែតៗៗ។
កៈ បាទ។
ខៈ ចាំ អាពុងតែសម្បូងអង្ករអីនិង។
កៈ បាទ ។
ខៈ
វាអោយយើងស៊ីឆ្អែតៗៗនិងរួចដល់ពេលធ្វើក្រោយទៀតនិងមុននិងក្រោយវានិងសំលាប់និងមកពីមិត្តយើងទៅស៊ីបាយព្រោះអីយើងអត់មានអីស៊ីស៊ីបបរ។
កៈ បាទ។
ខៈ តាមគេទៅវាយកយើងទៅសំលាប់និង។
កៈ បាទ។
ខៈ
នែកមិត្តយើងកំពុងស៊ីបាយនិងថាយើងនិងអត់មានអីស៊ីយើងស៊ីបបរនិងយើងទៅតាមគេទៅ។
កៈ បាទ។
ខៈ តាមពិតវាយកយើងទៅសំលាប់។
កៈ បាទ។
ខៈ អានិងវាអញ្ចឹង។
កៈ
ភាសាដែលគេយកទៅសំលាប់គេចូលចិត្តប្រើពាក្រយកទៅរៀនសូត្រយកទៅក៏សាងត្រូវទេអ៊ំអត់?
ខៈ វាអត់មានថាក៏សាងអីទេវាថាចែកយកទៅអោយស៊ីបាយ។
កៈ អ៊ើរយកទៅស៊ីបា្វ។
ខៈ ហើយយើងកំពុងតែឃ្លាន។
កៈ បាទ។
ខៈ យើងវាឃ្លានទៅរកស៊ីបាយ។
កៈ អ៊ើរចឹងគេប្រើពាក្រទៅរកស៊ីបាយមានន័យថាទើងតែបាត់ខ្ទុ្យនតែម្តង។
ខៈ យកទៅសំលាប់ចោលដឹងតែបាត់ខ្ទុ្យន។

ក៖
អ៊ំមានអីចង់និយាយប្រាប់កូនចៅជំនាន់ចុងក្រោយមានអីប្រាប់បន្ថែមទៀតទេពីជនាន់ពុលពត
និងដែលមានដែលមានពាក្រពេចន៍ចង់ផ្តែរផ្តាំសំរាប់មនុស្សជំនាន់ក្រោយអោយបានដឹង?
ខ៖ អ៊ើរ ប្រាប់ប្រាប់មនុស្សជំនាន់ក្រោយកអោយគេភ្លេីតភ្លេីន។
ក៖ បាទ។
ខ៖ ដូចជាជក់ថ្នាំញៀន។
ក៖ បាទ។
ខ៖ ក៏ដូចជាលេងជល់មាន់ជល់អីនិងកំអោយកេីតដូចជាជំនាន់អាពតទៀត។
ក៖ បាទ។
ខ៖ វេទនាណាស់។
ក៖ វេទនាណាស់។
ខ៖ ចាំ អោយខំរកខំប្រឹងធ្វេីទៅ។
ក៖ នៅក្នុងរយះពេលក្នុងឆ្នាំពឆ្នាំប្រាំបីខែមួយភែថ្ងៃនិងមានថ្ងៃដែលគិតថាចង់រស់ទេ?
ខ៖ ជំនាន់ពុលពត។
ក៖ បាទ។
ខ៖ មិនមានពីណាចង់រស់ទេនៅក្នុងជំនាន់ពុលពតទេចង់តែងាប់។
ក៖ ចង់តែងាប់។
ខ៖ ចាំ ។
ក៖ បាទ។
ខ៖
ចង់តែងាប់ព្រោះអីវាវេទនាណាស់វាវែទនាទាំងការហូបចុកគ្មានបានដេីរគ្មានបានឃេីញមាន
សិទ្ធសេរិភាពពិណាទេ។
ក៖ បាទ។
ខ៖ ។
ក៖ ដែលនឹកស្រមៃថាមានដែលនឹកឃេីញថានិងបានរួចផុតពីពិភពដែលខ្មៅងងឹតនិងអត់?
ខ៖ ខ្ញុំចេះតែថាដឹងកាលពួកអាពតវារលាយទៅ។
ក៖ បាទ។
ខ៖ រួចដល់ពេលចឹងទៅមានតែគុណម៉ែគុណឪអោយជួយទៅអោយអាពតវារលាយទៅ។
ក៖ បាទ។
ខ៖ ចេះតែផ្សងរាល់តែថ្ងៃចឹងទៅ។
ក៖ បាទ។

ខ៖ រួចទៅវាបានរលាយមែន។
ក៖ បាទរយៈពេលបីឆ្នាំប្រាំបីខែមួយភែថ្ងៃនិងទៅ។
ខ៖ ចាំ ។
ក៖ ហើយវាក៏បានរលាយចេញពីស្រុកខ្មែរយើងទៅ។
ខ៖ បានខ្ញុំបានមកស្រុកមកទេស។
ក៖ បាទ។
ខ៖
ហើយរួចដល់ពេលមកវីញណាក្មួយអើយអាដែងលីតាយកតែអំបិលហើយនិងភួយនិងនិងរបស់ហូបនិងម៉ែខ្ញុំគាត់ចាស់ហើយប្ដីនៅឯបែកនៅយួនហ្មេះ។
ក៖ បាទ។
ខ៖ អាពេលដែលគេចូលមកនិងយួនចូលពេញនិងខ្ញុំនិងរែកខ្ញុំរែកដាដ់អង្រែចឹង។
ក៖ បាទ។
ខ៖
រួយហើយដល់ពេលដែលឈឺស្មារពេកមានតែធ្វើអញ្ចឹងរួយដល់ពេលចឹងទៅដល់ពេលចឹងទៅខ្ញុំបានទូរអញ្ចេះ។
ក៖ បាទ។
ខ៖ ខ្ញុំបានទូរអាឡាក់១១១២ចឹងទៅ។
ក៖ បាទ។
ខ៖ រែកមុខរែកក្រោយ។
ក៖ បាទ។
ខ៖ ពួកនិងគេថាពួកនិងគេថាមើលប្រពន្ធតាស៊ូនិងឆ្កួតទេមើលទៅ។
ក៖ បាទ។
ខ៖ ថាឆ្កួតអីមីត្របល់យរអីមីនិង។
ក៖ បាទ។
ខ៖ ប៉ោងស្មារអស់ហើយ។
ក៖
អរអ៊ំខ្ញុំចង់សួរមួយខ្ញុំចង់សួរថាប្អូនប្រុសអ៊ំននិងឬក៏បងប្រុសរបស់អ៊ំនិងដែលបានស្លាប់នៅក្នុងសមយ៏ពុលពតនិង?ប្អូនឬក៏បង?
ខ៖ បងខ្ញុំ។
ក៖ បង។
ខ៖ បងប្ដីជាទាហ៊ាន។

កៈ គាត់ស្លាប់ដោយសារអីគេដែលអ៊ំ?

ខៈ

ស្លាប់និងចែកស្លាប់និងប្ដីធ្វើជាទាហ៊ាននិងគេរកអ្នកចេះដឹងអ្នកចេះធ្វើជាទ៊ាននិងគេយកទៅវ៉ៃចោលនិង។

កៈ បាត។

ខៈ ដល់ពេលចឹងទៅគេក៏យកប្រពន្ធយកទៅវ៉ៃចោលតាមក្រោយ។

កៈ បាទ។

កៈ ចុះគាត់បានស្លាប់នៅក្នុងឆ្នាំមួយណាដែល?៧៥ ៧៦ ៧៧?

ខៈ អញ្ចែកជិតប៉ុន្មាទេបើមុនមុននិងគេធ្វើទៅរំដោះនិងវាបានសំលាប់អ្នកចេះដឹងមុននិង។

កៈ បាទ។

ខៈ ចាំ ខ្ញុំអត់បានដឹងថាឆ្នាំប៉ុន្មានទេខ្ញុំអត់បានដឹងទេ។

កៈ បាទ។ចុះបើគ្រាន់តែគ្រាន់តែជាប្រពន្ធរបស់អ្នកដែលចេះដឹងក៏ត្រូវបានគេសំលាប់ដែល?

ខៈ ចាំ ហើយតែមានឈ្មោះថាជាអ្នកបានធ្វើជាទាហ៊ាន។

ខៈព្រោះអ្នកដែលបានចេះធ្វើជាទាហ៊ានបើតទុកអោយវានៅនាំតែយកមកបាញ់វាបានជាយកយើងទៅសំលាប់ចោល។

កៈ បាទ។

កៈ ចុះអ៊ំបានអានិតបងអត់ពេលដែលចឹងទៅ?នៅពេលដែលលឺចឹងមានខ្លោចចិត្តអីអត់?

ខៈ និយាយថាមិនខ្លោចចិត្តម៉ិចក្មួយអើយមកដល់ទៅមានបងមានប្អូនណាស្លាប់អស់រលីង។

កៈ បាាទ។

កៈអញចឹងសំរាប់សមយ័ពុលពតគឺបានបន្សល់នៅភាពឈឺចាប់ជាច្រើនណាស់អ៊ំ?

ខៈ

មានតែបីអ្នកទេស្រីមួប្រុសមួយអត់ទេស្រី២ប្រុសមួយរួចដល់ពេលចឹងបងខ្ញុំគាត់បានស្លាប់បងស្រីនិងគាត់បានស្លាប់ទៀតខ្ញុំក៏មកនិងខ្ញុំមក។

កៈ ម្នាក់ឯងសុទ្ធ។

ខៈ តែម្នាក់ឯង។

កៈ

អញ្ចឹងខ្ញុំចង់រំលេងអាសមយ័ពុលពតមកដល់ថ្ងៃដែលកៀកបែកវិញថាតើនៅពេលដែលកៀកបែកនិងមានបានលេចលឺថាដែលមានភាពជាក់លាក់ណាមួយថាមានគេវាយចូលមកហើយមានកងតព័ខាងកងទព័វៀតណាមនិងបានឈ្លៀនពាន។

ខៈ អាដែងកងទព័វៀតណាមចូលមកនិងណា។

កៈ រួចទៅអាពតវាថាមមិត្តយើងហ្នកពួកយើងមើលន់យួនវាវ៉ៃចូលហើយ។

កៈ បាទ។
ខៈ
បើយើងមិនសំលាប់វាវានិងសំលាប់យើងព្រោះវាចងនិងកករហើយអោយខ្មែរវាងនិងនិងណា
។
កៈ បាទ។
ខៈ ចេះតែឃោសនាចឹងហើយរួយដល់តែពេល។
កៈ បាទ។
ខៈ ធ្វើចឹងទៅហើយអ្នកនោះចេះតែភយ័។
កៈ បាទ។
ខៈ ចេះតែភយ័ចឹងទៅមានតែទៅតាមវាទៅ។
កៈបាទ។
ខៈ ចាំ។
កៈ
តែសំរាប់កងទព័វាតណាមដែលចូលមកវាដូចចាអត់សំលាប់ប្រជាពរដ្ឋស្លូតត្រង់ទេវាសំលាប់
តែកងទព័របស់ពុលពតនិងទេ?
ខៈ អានេះខ្ញុំមិននិយាយថាកាន់ជើងកាន់ដៃអីទេណា។
កៈ បាទ។
ខៈ ពេលដែលខ្ញុំចូលទៅជំលាសនិងនែកទៅនិងយួននិងចេះតែឌីៗៗៗៗទៅមុខ។
កៈ ឌីទៅបកប្រែជាភាសាខ្មែរថាទៅ។
ខៈ ឌីនិងអោយយើងមកនែក។
កៈ ឌីមានន័យថាទៅ។
ខៈ មកក្រោយ។
កៈ បាទ។
ខៈ ចាំមកក្រោយបើសិនជាអាពតនិងវាខ្លាំងវាខ្លាំងនិងប្រជាជននិងវាផ្ដឹង។
កៈ បាទ។
ខៈ គេអោយគេអត់មានសំលាប់អីទេគេយកទៅដាក់គុក។
កៈ បាទ។
ខៈ គេចាប់យកទៅដាក់គុក។
កៈ បាទ។
ខៈ អត់មានយួននិងបានបាញ់អីភ្លាមៗៗអីទេគេមិនសំលាប់អីទេណា។
កៈ បាទ។

ខ៖ យកមកតាមផ្លូវច្បាប់។
ក៖ បាទ។
ខ៖ អញ្ចឹងនៅពេលដែលយួនចូលមកនិងអ៊ំនៅចាំឆ្នាំណាដែលជាក់លាក់អីទេអ៊ំ?
ខ៖ ឆ្នាំនិងអ៊ំអត់ដឹងទេក្មួយ។
ក៖ អត់ចាំទេ។
ខ៖ ចាំ អត់ចាំទេ។
ក៖
នៅពេលដែលយួនមកដល់ពិបចឹងថាតើអាពួកមេធំៗៗនិងជាកងរបស់ពុលពតនិងវាធ្វើម៉ិចដែល?
ខ៖ វាមិនដឹងថាធ្វើយ៉ោងម៉ិចដែលវាបានគេច។
ក៖ វាគេចខ្លួន។
ខ៖ ចាំវាគេចហើយដល់ពេលដែលវាខ្លាំងទៅប្រជាចនបានផ្តឹង។
ក៖ ប្រជាជនបានផ្តឹង។
ខ៖៖ ផ្តឹងផ្តឹងទៅថាអានេះមេកងអានេះមេកងខ្លាំង។
ក៖ បាទ។
ខ៖ ចង្អុលទៅគេចាប់ដាក់ឡានទៅ។
ក៖ បាទ។
ខ៖ យកដាក់គុកទៅ។
ខ៖ ចាំ។
ក៖ បាទ។
ក៖
ប៉ុន្តែតែដែលមានបានឃើញទិដ្ឋភាពមួយដែលពេលដែលពួកប្រជាពលរដ្ឋបានព្រួតគ្នាសំលាប់ពួកអាមេកងនិងអត់ដោយសា?
ខ៖ អ៊ើរប្រជាជននិងខឹងណាស់។
ក៖ បាទ។
ខ៖ ខឹងណាស់ជួនកាលទាញដំបងវ៉ៃទៅហើយក៏ងាប់ទៅក៏មានដែល។
ក៖ បាទ។
ខ៖ ប៉ុន្តែគេអត់អោយវ៉ៃ។
ក៖ បាទ។

ខ៖
ជូនកាលពេលដែលអត់ឃើញទេអត់អីទេតែដដល់ពេលឃើញទៅគេអត់អោយវ៉ៃទេគេយកទៅ
ដាក់គុក។
ក៖ បាទ។
ខ៖ តែប្រជាជនទ្រាំមិនបានវ៉ៃដែលនិងព្រោះទ្រាំមិនបាន។
ក៖ បាទ។
ខ៖ ទ្រាំមិនបាន។
ក៖ដោយសារប្រជាជនខឹង។
ខ៖ ចាំហ្នឹងហើយ។
ក៖
ដោយសារកាលកនៅក្រោមកាលគ្រប់គ្រងរបស់មេកងនិងគេបានយកមនុស្សទៅសំលាប់ចោ
លច្រើនណាស់។
ខ៖ ចាំវាធ្វើបាប ។
ក៖ អញ្ចឹងពួកគេខឹងនិងណា។
ខ៖ ចាំ។
ក៖
អញ្ចឹមានអ្នកខខ្លះគេថាមេកងនៅក្នុងសមយ័និងភាគច្រើនស្លាប់ដោយសារតែប្រជាជននៅក្នុង
សមយ័និងសំលាប់ព្រួតគ្នាដើម្បីវ៉ៃនិងតែម្តង?
ខ៖
ថាជួនកាលវ៉ៃនិងណាតែដូចជាខ្ញុំនិយាយចឹងជូនកាលខឹងទៅឧបមាថាចេះអានេះម្នាក់អីទេអ
ស់ពីនិងទៅ។
ក៖បាទ។
ខ៖ អស់ពីនិងទៅពួកបងប្អូនវៀតណាមអត់អោយវ៉ៃទេ។
ក៖ បាទ។
ខ៖ គេយកទៅដាក់គុក។
ក៖ បាទ។
ខ៖ ចាំ។
ក៖
ចុះអ៊ំដែលដែលដែលដែលប្រទេះឃើញការបាញ់គ្នារវាងពួកកងទព័ពុលពតនិងវៀតណាមនិង
ត់ដូចជាបាញ់ដោយសារតែកាំភ្លើងអីនិងតទល់គ្នាដូចជាសង្គ្រាមអីនិងណា?
ខ៖ អានិងបាញ់និងប្តីខ្ញុំបានគាត់នេះនែក។

កៈ បាទ។
ខៈ
ហើយពេលដែលបាញ់ទៅក៏ពេលដែលពួកបងប្អូនវៀតណាមថាចូលចូលចូលមិត្តយើងចូល
ហើយដល់ពេលដែលពួកយើងចូលអញ្ចឹងដល់ពេលដែលរត់ចូលទៅជ្រល់ទៅដល់ពេលហើយ
ដល់ពេលពួកវៀតណាមលើកទង់ជយ័លើអីចឹងទៅ។
កៈ បាទ។
ខៈ ខ្ញុំបានលឺតាមប្តីខ្ញុំព្រោះថាខ្ញុំអត់បាននៅក្នុងសមរភូមិនិងទេ។
កៈ បាទ។
ខៈ ចាំ ។
កៈ
មានអីរមានមានកងទព័ឬក៏ប្រជាជនដែលអីរដូចជាបានចុះចូលជាមួយវាតណាមច្រើនិទេនៅ
ក្នុងជំនាន់និង?
ខៈ អីរៗចុះចូលច្រើនតើ។
កៈ បាទ។
ខៈ ព្រោះតែចុះចូលនិងទើបបានមកស្រុកទេសវិញបាននិង។
កៈ បាទ។
កៈ បើមិនចុះចូលទេពួកអាពតវានាំប្រទេស។
ខៈ ចេះតែទៅទៀត។
កៈ ចេះតែទៅទៀតទៅ។
ខៈ ព្រោះយើងបកក្រោយ។
កៈ បាត។
ខៈ អត់មានរល់ទៅតាមវា។
កៈ បាទ។
កៈ ពលពុលបានថយរហូតទោដល់ប៉ៃលិននិងត្រូវមែនទេអ៊ំ?
ខៈ អីរវានិងចេះតែទៅទៅៗវាទៅរហូតមិនដឹងជាវាទៅទីណាទេ។
កៈ បាទ។
ខៈ ទៅដល់ភ្នំដល់អីទៅ។
កៈ បាទ។
ខៈ ហើយយើងក៏បកមកក្រោយវិញមក។

កៈ
អញចឹងនិយាយអំពីទិដ្ឋភាពអំពីការត្រលប់មកផ្ទះវិញតើត្រូវបានគេបានបែងចែកថាយើងត្រូវបានត្រលប់មកផ្ទះឬក៏យើងគិតថាវៀតណាមមកជួយហើយអញ្ចឹងយើងដើរមកផ្ទះវិញធម្មតា?
ខៈ គាត់បើស្រុកទេសយើងនៅឯណាគាត់យើងទៅតាមផ្ទះយើង។
កៈ បាទ។
ខៈ ចាំ ថាមកដូចថាកន្លែងយើងនៅឯណាយើងមកនៅកន្លែងយើងនិងវិញទៅ។
កៈ បាទ។
ខៈ នៅកន្លែងណាមកនៅកន្លែងនិងវិញទៅ។
ខៈ ចាំ ។
កៈអញ្ចឹត្រូវការសំគេដែលដើម្បីដើរមកកន្លែងផ្ទះយើងវិញឬក៏យើងគ្រាន់តែដើរមកខ្លួនឯង?
ខៈ អត់មានសំអីទេ។
កៈ អត់មានទេ។
ខៈ
ធ្វើតាមសេរីដូចជាយើងបើយើងយើងផ្ទះសំបែងយើងនៅឯណាមកកន្លែងវិញមកគាត់អត់មានបានហាមឃាត់ទេ។
កៈ បាទ។
ខៈ
អត់មានទេអត់មានហាមអត់អោយទៅស្រុកទេវិញទេអត់មានទេអត់អោយទៅទេអោយទៅដេកទីរនោះដេកទីរនេះអត់មានទេ។
កៈ បាទអត់ាមានទេ។
ខៈ ចាំ
ចុះអាពេលដែលពីពោសាធន៍មកដលផ្ទះវិញមកដល់អាកោះដដាច់និងវិញថាតើត្រូវប្រើរយៈពេលប៉ុន្មានថ្ងៃទើបបានមកដល់?
ខៈ ពោសាធន៍និងមកនិងវាបានដេកផ្លូវតែមួយយប់ទេ។
កៈ ដេកផ្លូវតែមួយយប់ទេ។
ខៈ ចាំ ដេកផ្លូវតែមួយយប់ទេហើយតែមួយយប់ទេ។
កៈ អញ្ចឹមាននយ័ថាអ៊ំមានបានជិះយានជំនិះអីមមកទេ?
ខៈ ជិះជិះឡានមក។
កៈ អញ្ចឹមានឧកាសបានជិះឡានមក។
ខៈ ចាំ បានចិះឡានមកបាជិះឡានមក។
កៈ ចុះឡាននិងប្រភេទអីគេដែលនៅសមយ័និងអ៊ំនៅចាំទេប្រភេទឡានប្រភេទអីគេដែល?

ខ៖ ឡានដូចជាឡានយើងឡានសព្វថ្ងៃយើនិងចឹង។
ក៖ បាទនិងហើយ។
ខ៖ អាឡានទ្រុងអីនិង។
ក៖ បាទ។
ក៖ ឡានទ្រុងធំៗៗៗនិងហ្មំ។
ក: អញ្ចឹអ៊ំធ្លាប់នៅពេលដែលច្រលំណៅពេលដែលអ៊ំបានមកជាមួយម្ដាយនិងជាមួយប្ដីទេអ៊ំ?
ខ៖ ខ្ញុំមកជាមួយម៉ែខ្ញុំជាមួយម៉ែខ្ញុំ។
ក៖ ប្ដីអត់បានមកទេជាមួយទេ។
ខ៖ ប្ដីខ្ញុំកាលនិងអាពេលមកនិងគាត់បានមកជាមួយគ្នាហើយ។
ក៖ ទាំងកូនបានមកជាមួយនិងដែល?
ខ៖ ចាំ. កូនអីបានមកទាំងអស់។
ក៖ បាទ។
ក៖ មកតែមួយគ្រួសាររបស់អ៊ំឬក៏មកមានគ្នា?
ខ៖ មកគ្នាច្រើន។
ក៖ គ្នាច្រើន។
ខ៖
ចាំពេលដេលពេលដែលជំលាសនិងពេលដេលបានមកនិងមកបានច្រើនមកពេញៗៗៗម៉ាឡានមក។
ក៖ អាចរៀបរាប់អំពីអារម្មណ៍សប្បាយនៅពេលបានអត់អ៊ំនៅពេលដែលបានមកផ្ទះវិញ?
ខ៖ ពេលនគិតថាបានមកផ្ទះមានអារម្មណ៍សប្បាយ។
ក៖ សប្បាយ។
ខ៖ ចាំ បានសប្បាយ។
ក៖ បានសប្បាយ។
ខ៖ មកដល់ស្រុកទេសគឺយើងមានសេរីភាពហើយ។
ក៖ មកវិញនិងបានជុះកាត់ទីក្រុងភ្នំពេញឬក៏មកកាត់តាមទឹកមក។
ខ៖ គឺមកតាមគឺបានឆ្លងដរនេះបាក់ខែងយើនិង។
ក៖ អញ្ចឹមានន័យថាអញ្ចឹមានន័យថាបានឆ្លងកាត់ទីក្រុងភ្នំពេញដែល?
ខ៖ចាំ ឆ្លងឆ្លងមកនិងគឺទូកទូកចំហៀង។
ក៖ បាទ។
ក៖ គិតថាទិដ្ឋភាពទីក្រុងភ្នំពេលនាពេលនិងយ៉ាងម៉ិចដែល?
ខ៖ កាលនិងភ្នំពេញខ្ញុំអត់បានទៅផង។

កៈ អត់បានទៅផង។
ខៈ ចាំខ្ញុំបានត្រឹមតែមកឯនេះ។
កៈបានត្រឹមតែមកឯនេះទេ។
ខៈ ចាំមកផ្ទះឯនេះទេ។
កៈ មកឯផ្ទះ។
កៈ
នៅពេលដែលបានមកផ្ទះដំបូងថាតើបានឃើញផ្ទះនៅដូចដើមឬក៏វាបានបាក់បែកខ្ទេចខ្ទីរអស់
។
ខៈ ពេលដែលមកដល់និងសុទ្ធតែទាហ៊ានក្នុងនៅ។
កៈ ទាហ៊ានក្នុង។
ខៈ ទាហ៊ានក្នុងនៅចឹងទៅទាហ៊ានក្នុងនិងនៅ។
កៈ ទាហ៊ានក្នុងម៉េចដែលអ៊ំ?
ខៈ ទាហ៊ានក្នុងនិងវាមានការិលធំៗៗៗ។
កៈ ម៉េចក៏ក្នុងនិងជាទាហ៊ានដែលជាទាហ៊ានរបស់ខ្មែរឬក៍ជាហ៊ានរបស់ក្រុមណាមួយ។
ខៈ
ក្នុងនិងជាទាហ៊ានខាងខាងអីគេទេនៀកពួកទាហ៊ាននិងគឺជាទាហ៊ានជំនាន់លុណណុលអីនិង
។
កៈ ចេះខ្មែរទេក្នុងនិង?
ខៈ អត់ចេះទេមកទៅដូចថាទាហ៊ានក្នុងនិង។
កៈ ទាហានក្នុងនិងហើយនិងទាហ៊ានវៀតណាមខុសគ្នាអត់?
ខៈ ខុសគ្នា។
កៈ តែការងាររបស់គេគឺជួយប្រទេសខ្មែរដូចគ្នា?
ខៈ អាពេលមកទៅគេធ្វើសំរាប់អីអាត្រង់សេអីគេនោះ។
កៈ បាទ។
ខៈ គេជីកដីជីកអីនិងជីកឡាំងក្រហាងក្រហូង។
កៈ បាទ។
ខៈ គេនៅកាលពេលនោះបាញ់បាញ់ពីនោះមកបាញ់គេធ្វើការពារគ្រាប់។
កៈ
ខ្ញុំនៅតែមានចង្ងល់អំពីអាទាហ៊ានក្នុងនិងបន្តិចទាហ៊ានក្នុងនិងប្រសិនបើជាទាហ៊ានវៀតណាម
បានជួបទាហ៊ានក្នុងនិងទាហ៊ានក្នុងនិងពួកគេបាញ់គ្នាទេ?
ខៈ ចាំ បាញ់។

កៈ បាញ់គ្នា។
ខៈ ចាំ បាញ់គ្នា។
កៈ ចុះមាននយ័ថាបក្រខុសគ្នា។
ខៈ បក្រខុសគ្នាព្រោះមួយជាទាហ៊ានភ្នងជំនាន់លុណណុល។
កៈ បាទ។
ខៈ រួចដែងនៃចំនែកទាហ៊ានទាហ៊ានវៀតណាមមករំដោះ។
កៈ តែទាហ៊ានភ្នងមានបានធ្វើបាបប្រជាជនខ្មែរទេ?
ខៈ
ព្រោះនៃទៅស្រុកនិងវានៅតែស្រុកវានៅតែពេលអាតាក់ធ្វើទព័បើអ្នកស្រុកអ្នកភូមិវាអត់អោយចូលស្រុកទេ។
កៈ បាទ។
ខៈ ចាំ វាមានអីវាយកទៅ។
កៈ អ៊ីរ។
ខៈ ចាំ។
ខៈ ប្រពន្ធកូនវាដូចជាមានទូរមានអីចឹងទៅវាចេះតែរំដោះយកអស់ទៅ។
កៈ បាទ។
កៈ អញ្ចឹងវា។
ខៈ វ៉ៃនៅណាវានៅនិង។
កៈ វាស្រដៀងតែចោលដែលចឹង។
ខៈ និងហើយ។
កៈ
ចោលដូចជាចោលវាវ៉ៃមួយភូមិនិងចឹងវាមកយកទ្រព័សម្បត្តរបស់អ្នកភូមិនៅកន្លែងនិងទាំងអស់។
ខៈ ចាំ ។
កៈ វាស្រដៀងនិងហៅថាចោលព្រៃនិងដែលចឹង។
កៈ អញ្ចឹនៅបេលដែលអ៊ំមកដល់បានឃើញពួកវាចឹងអ៊ំបានធ្វើយ៉ាងម៉ិចទើបបានធ្វើផ្ទះ?
ខៈ អត់ហ៊ានចូល។
កៈ អត់ហ៊ានចូលទេ។
ខៈ ចាំ ។
ខៈអត់ហ៊ាមចូលទេរួចបើខ្ញុំមកផ្ទះចឹងវាថាវានិយាយដូចជាថាបើអោយខ្លួនប្រាណទៅវាទើបវាអោយចូលលឺតែចឹងខ្ញុំជិះកង់បោលខ្ញុំអត់ហ៊ានចូលទេ។

កៈ បាទ អញ្ចឹអ៊ំប៉ុន្មាថ្ងៃប៉ុន្មានខែក្រោយមកទើបបានទើបអាចចូលក្នុងផ្ទះបាន?
ខៈ ទាល់តែបែកភ្នំពេញនិង។
កៈ ទាល់តែបែកម៉ង។
ខៈ ចាំ បែកពេញទើបបានចូលក្នុងផ្ទះ។
កៈ បានចូលផ្ទះវិញ។
ខៈ ចាំ ។
កៈ អញ្ចឹងអាមកពីពោសាធន៏ហើយថាតើអ៊ំស្នាក់នៅកន្លែងណាមួយផ្សេងទៀត?
ខៈ មកដល់ពោសាធន៏និងខ្ញុំមកដល់ផ្ទះខ្ញុំតែម្តង។
កៈ មកដល់ផ្ទះនិង។
ខៈ ចាំ ។
ខៈមកដល់ផ្ទះ។
កៈ ចុះផ្ទះនិងមានបាក់បែកខូចខាតអីអត់?
ខៈ ដូចខ្ញុំនិយាយចឹងអត់មានខូចខាតអីទេគ្រាន់តែថាគេជីកដីក្រហូង។
កៈ បាទ។
ខៈ គេធ្វើអាត្រង់សេ។
កៈ មានទឹកភ្នែកអីអត់ពេលដែលបានត្រលប់មកផ្ទះអីវិញអីនិង?
ខៈ និយាយមិនទឹកភ្នែកម៉េចលោកអើយ។
កៈ ស្រណោះនឹកផ្ទះ។
ខៈ មកដល់បែកបងបែកប្អូនអស់រលីងស្លាប់អស់រលីងអាមកដល់ទ្រហ៊ុរយំ។
កៈ បាទ។
ខៈ ចាំ។
កៈ ម៉ាក់របស់អ៊ំម៉ិចដែលពេលនិង?
ខៈ ម៉ែខ្ញុំគាត់មកជាមួយខ្ញុំមានអី។
កៈ គាត់សោកស្តាយអី?
ខៈ ចាំ បាត់អាបង។
កៈ បាទបាត់អាបងមួយ។
ខៈ បើនៅភ្នំពេញហ្មោះអីហ្មោះគាត់ស្លាប់តាំងពីខ្ញុំនៅភ្នំពេញនិងមក។
កៈបាត។
ខៈ បងរិនមួយហ្មោះ។
កៈ បាទ។

ខ៖
ឯបងហ្មេះកាលមកនិងថាអាងអាបងគាត់នៅផ្ទះមកដល់ផ្ទះបងឯងគេយកទៅសំលាប់ចោលអស់ហើយ។
ក៖ អឺរ។
ខ៖ ទ្រហ៊ារយំ។
ក៖ ទ្រហ៊ារយំ។
ក៖ ម៉ាក់អ៊ំគាត់ស្មារតីគាត់រឹងមាំចឹងគាត់អត់មានជំងឺផ្លូវចិត្តអីអ្នកមីងនៅពេលនិង?
ខ៖ គាត់ស្រែកទ្រហ៊ារយំដែលគាត់បាត់កូនបាត់អីអស់។
ក៖ បាទ។
ក៖ ហើយនៅពេលដែលមកដល់ផ្ទះដំបូងការងារដំបូងធ្វើអីគេដែលពេលមកដល់ផ្ទះភ្លាមនិង?
ខ៖ មកដល់ផ្ទះនិងប្តីខ្ញុំគាត់វិញខ្សែរ។
ក៖ គាត់វិញខ្សែរ។
ខ៖ គាត់វិញខ្សែរដូរជាពោតដូរជាអីនិង។
ក៖ បាទ។
ខ៖
ដូរចាពោតជាអីចឹងដល់ពេលចឹងហើយពេលចឹងដល់ពេលបានលុយទៅធ្វើកាំបិតត្នោតចាប់ផ្តើមឡើងត្នោត។
ក៖ឡើងត្នោត។
ខ៖ ចិញ្ចឹមជិវិត។
ក៖ តែឥលូវដូចអត់ឃើញមានដើមត្នោតផង?
ខ៖ ដើមត្នោតនិងគេកាប់ចោលអស់ហើយ។
ក៖ បាទ។
ខ៖ ដើមត្នោតខ្ញុំនិងនៅឡាំងច្រើន។
ក៖ បាទ។
ខ៖ គេកាប់ចោលអស់ហើយ។
ក៖ ហើយខាងប្តីរបស់អ៊ំវិញគាត់បានទៅរកមើលឪពុកម្តាយបងប្អូនសាច់ញាតិរបស់គាត់អីទេ?
ខ៖ អើគាត់ដឹងថាឪពុកគាត់ស្លាប់អស់ហើយ។
ក៖ ស្លាប់អស់ហើយ។
ខ៖ ចាំស្លាប់ជំនាន់អាពតប្អូនក៏ស្លាប់នៅក្នុងជំនាន់អាពតដែលព្រោះតែកើតំបៅលេច។
ក៖ បាទ។
ខ៖ ចាំតែបែកគ្នានស្រុកខុសគ្នា។

កៈ នៅស្រុកខុសគ្នា។
ខៈ ចាំ។
កៈ អញ្ចឹងគាត់ស្លាប់អស់ហើយចឹងក៏លែងទៅរកអ្នកដែលនៅសល់ទៀត។
ខៈ ចាំ គាត់មកនៅតែខាង។
កៈ ខាងអ៊ំតែម្តង។
ខៈ ខាងម៉ែខាងអីខ្ញុំនៅនិងតែរហូត។
កៈ បាទ
អញ្ចឹងអូរឿងមួយដែលខ្ញុំភ្លេចសួរអ៊ំលឺថាសមយ័ពុលគេថាគេចាប់រៀបការជាគូររាប់រយគូរចឹងដែលឃើញទេ?
ខៈ ដូចថាដូចអ្នកណាដូចក្មួយឯងស្រលាញ់ចឹងទៅស្នើរអង្គការ។
កៈ បាទ។
ខៈ
ស្នើរអង្គការថាខ្ញុំស្រលាញើអ្នកនេះខ្ញុំស្រលាញ់អ្នកនោះរបើសិននារីនោះប្រកែកគឺយកវ៉ៃចោល។
កៈ បាទ។
ខៈ
ចាំអាដែងដូចថាគេរៀបជាគូរៗនិងម្តង១០គូរខ្ញុំផ្តាច់ផ្ការថាស្រលាញ់ខ្ញមួយឯងចឹងនិងណា។
កៈ បាទ។
ខៈ យកជាអនាគតដល់ពេលចឹងទៅ១០គូរ២០គូរចឹងទៅ។
កៈ បាទ។
ខៈ រួចទៅពាក់ស្បែកជើងកង់ឡានក្រមាក្រហមយើងនិង។
កៈ បាទ។
ខៈ ហើយនិងសក់ការ៉េ។
កៈ បាទ។
ខៈ ខោកៅស៊ូ។
កៈ បាទ។
ខៈ ខោខ្មៅអាវខ្មៅនិងឡើងទៅផ្តាច់ផ្ការថា។
កៈ បាទ។
ខៈ ខ្ញុំផ្តាច់ផ្ការថាស្រលាញ់ចេះចុះអីចឹង។
កៈ បាទ។
ខៈ អស់មួយជិវិតចឹងទៅ។

កះ ហើយមានដែលមានដូចជាពិធីការរបស់គេសមយ័មានតែប៉ុន្នឹង?
ខះ មានដែប៉ុន្នឹង។
កះ អត់មានអត់មានដូចជាសែនព្រេងដូចខ្មែរ។
ខះ អត់មានសែនព្រេងអត់មានព្រេងអីទេចាប់ឡើងផ្តាច់ជ្ជារួចហើយ។
កះ ហើយយកទៅផ្ទញទៅ។
ខះ យកទៅផ្ទះទៅ។
កះ ហើយដែលលឺគេថាដូចជាបើប្តីប្រពន្ធនិងដូចជាអត់ស្រលាញ់គ្នាអីចឹងមានដូចជា។
ខះ អត់ស្រលាញ់គ្នា។
កះ មានដូចជាពួកឈ្លបលបៗទៅដឹងចឹងយកទៅសំលាប់ចោលទេ?
ខះ ចាំ បើឈ្លបដឹងដល់ឈ្លបនិងដឹងថាអត់ស្រលាញ់គ្នាវាយកទៅសំលាប់ចោល។
កះ សំលាប់ចោល។
ខះ ចាំ ។
កះ ចុះបើឈ្លបនិងចេះតែនិយាយអី?
ខះ អត់មាននេះទេគេសុទ្ធតែស៊ើប។
កះ ស៊ើបៗមើល។
ខះ ចាំ ថាអ្នកឯងមិនមិនស្អីមិនស្មោះនិងអង្គការ។
កះ បាទ។
ខះ អ្នកឯងក្បត់និងអង្គការចឹងអីទៅ។
កះ ក្បត់ពីអង្គការ។
ខះ និងហើយ។
កះ ចុះអ៊ំនៅពេលដែលបានមកដល់ផ្ទះវិញប្តីអ៊ំឡើងត្នោតអ៊ំធ្វើអីដែល?
ខះ ខ្ញុំនៅពេលនិងស្ករអីគេគេយកមកលក់។
កះ ស្ករ។
ខះ យកមកលក់ទៅម៉ូយគេដាក់តាមផ្ទះនិងណា។
កះ បាទ។
ខះ ចាំតាមផ្ទះចឹងទៅចាប់ផ្តើមធ្វើ។
កះ
សួរបកមកក្រោយវិញការលក់នៅដូរនៅក្នុងសមយ័និងដោយការដោះដូររបស់ឬក៏មានលុយកាក់ឬក៏អីមួយ?
ខះ កាលពីជំនាន់និង។
កះ បែកពីអាពតភ្លាមនិង។

ខ៖ បែកពីភ្នំពេញមកនិងព្រោះគេមានម៉ូយដាក់។
ក៖ បាទ។
ខ៖ អត់មានអត់មានលុយអត់អត់មានអីទេ។
ក៖ បាទអត់មានលុយទេ។
ខ៖ ចា៎ ដូចដាក់សូត្រមួយកាលីចឹង។
ក៖ ស្មើរនិងអង្ករប៉ុន្មានដែល?
ខ៖ កាត់សំពត់ចឹងទៅ។
ក៖ បាទ។
ខ៖ សងម៉ូយ ហើយបើយើងត្រូវការអីឥលូវខ្ញុំត្រូវការមួយម៉ឺនពីម៉ឺនយកមកចាយក្រៅមកណា។
ក៖ បាទ។
ខ៖ ហើយសំពត់និងយើងយកអោយគេទៅ។
ក៖ បាទ។
ខ៖ ចា៎ មាន។
ក៖ សំរាប់សសៃសូត្របានមកពីណាវិញ?
ខ៖ សសៃសូត្រនិងយកពីណាទេយកពីស្រុកយួនមក។
ក៖ យកវាមក អ៊ំអត់ជាអ្នកធ្វើពីដាំមួងជាអីអត់ដែលធ្វើអនិងណាអ៊ំអី?
ខ៖ ធើយើងធើអានិងយើងធ្វើជាដង្កូវនាងផ្សេងអីធ្វើអត់កើតទេ។
ក៖ ធ្វើអត់កើតទេ។
ខ៖ ចា៎ ទិញពីវាបងប្អូនវៀតណាម។
ក៖ បាទ
ចុះនៅពេលដែលបែកអាពតហើយបែកថាបែកភ្នំពេញហើយមកដល់ផ្ទះអីចឹងអ៊ំបានមានកូនប៉ុន្មានទៀតពេលនិង?
ខ៖ ពេលនិងខ្ញុំអត់មានកូនទៀតទេអស់ហើយ។
ក៖ អស់ហើយ។
ខ៖ ចា៎ ។
ក៖ ចុះកូនអ៊ំមកដល់ឥលូវមានប៉ុន្មានអ្នកដែល?
ខ៖ កូនខ្ញុំនោះកូនស្រីពីហើយឥលូវស្លាប់អស់មួយហើយ។
ក៖ បាទ។
ខ៖ ចា៎ សល់តែបីទេ។

កៈ បាទ
អញ្ចឹងនៅពេលដែលបែកមកភ្លាមអីចឹងទៅអ៊ំអោយកូនចូលរៀនរក៏អោយកូននៅមើផ្ទះពេលនិង។
ខៈ កូនខ្ញុំតេដល់ពេលនេះវាធំៗៗអស់ហើយវាមានប្តីមានប្រពន្ធអស់ហើយ។
កៈ អ៊ើរ។
ខៈ ចា៎ នៅពេលមកនិងវាមានប្តីមានប្រពន្ធអស់ហើយ។
កៈ អ៊ើរចឹង។
ខៈ
អត់មានអាចរៀនអីទេរៀនបានតិចៗណាស់ដូចខ្ញុំបាននិយាយចឹងថ្នាក់ទីរប្រាំទីរប្រាំមួយអីទេ។
កៈ បាទ ។
ខៈ ម៉ែឪក្រមិនអាចមានលុយតស៊ូរអោយកូនបានរៀនច្រើនទេ។
កៈ បាទ។
កៈ
នៅពេលដែលក្រោយសម័យពុលពតនិងពេលបែកអាពតនិងគែហៅសម័យអីគេដែលកាលនៅសម័យនិង?
ខៈ សម័យពុលពតនិងគេហៅសម័យអីគេទេខ្ញុំអត់សូវចាំទេ។
កៈ អត់សូវចាំទេ។
កៈ ចា៎ ។
កៈ
ចុះយើងនិយាយអ្វីដែលម៉ោលមុខទៀតវិញផុតពីសម័យពុលពតនិងមកអ៊ំនៅផ្ទះអ៊ំធ្វើការត្បាញ។
ខៈ ខ្ញុំត្បាញហើយប្តីខ្ញុំគាតើឡើងត្នោត។
កៈ ឡើងត្នោត។
ខៈ ធ្វើចំការ។
កៈ ធ្វើចំការធ្វើអី។
ខៈ ពាយមងពាយអីតស៊ូចញ្ចឹមជិវិត។
កៈ ជិវភាពនៅតែធ្វើការងារកសិកម្ម។
ខៈ ចា៎ ។
កៈ ធ្វើការធ្វើនិងការលក់ដូរអីចឹង។
ខៈ ចា៎។
កៈ តិចតួចនិង។

ខ៖ គ្រាន់តែយើងមានសេរីភាព។
ក៖ បាទមានសេរីភាព។
ខ៖ មានសេរីភាពយើងយើងហូបចុកអី។
ក៖ គ្រប់គ្រាន់។
ខ៖ ដោយខ្លួនយើង។
ក៖បាទ។
ខ៖ មិនអាចថាជំនាន់អាពតអាពតវាគ្រប់គ្រងមិនអោយយើងស៊ី។
ក៖ បាទឥលូវននិងយើងបានបែកទៅយើងបានញុំាអី។
ខ៖ មានសេរីភាព។
ក៖ បានញុំាអីតាមចិត្តវិញ។
ខ៖ ចា៎ ។
ក៖ សុខភាពយើងក៏មាំជាងមុន។
ខ៖និងហើយ។
ក៖
ហើយចុះយើងផ្លាយមកដល់សមយ័មួយទៀតវិញដែលសមយ័និងក៏មានអ្នកស្លាប់អស់ជាច្រើនដែលគេហៅថាសមយ័ករប្រាំអ៊ំដែលលឺអំពីសមយ័ករប្រាំនិងអត់?
ខ៖ ចា៎សមយ័ក៏ប្រាំ ប្តីខ្ញុំគាត់ទៅករប្រាំស្លាប់មួយសារទៀត។
ក៖ បាទ។
ខ៖ ព្រោះអោយទៅកាលនិងអោយទៅធ្វើអីទេ។
ក៖ ទៅដូចជា។
ខ៖ សមយ័ករប្រាំតែពេលដែលមកវិញ។
ក៖ ដោះមិនដោះអីនិង។
ខ៖ ដោះមិនក៏ស្លាប់មិនដោះមិនក៏គ្រុណចាញ់។
ក៖ បាទ គ្រុណចាញ់។
ខ៖ តែដល់ពេលខ្ញុំនិងខ្ញុំជួលគេអស់មាសបួនជីរទៅ។
ក៖ បាទ។
ខ៖ ប្តីខ្ញុំរួចខ្លួន។
ក៖ បាទ។
ខ៖ ចា៎
អ៊ំចាំអំពីទិដ្ធភាពពេលនិងកាលចាប់អោយធ្វើជាទាហ៊ានករប្រាំនិងតាមកាលចាប់បង្ខំឬក៏ដោយសារការស្មគ្រ័ចិត្ត។

ខ៖ អ៊រកាលនិងគេត្រូវតែត្រូវតែដាក់ទិសចឹងម៉ង។
ក៖ បាទត្រូវតែទៅតែម្ដង?
ខ៖ ចាំ ត្រូវតែទៅ។
ក៖ បើអត់។
ខ៖ បើមានការចាំបាច់ហើយ។
ក៖ បាទ។
ខ៖ ចាំ ខ្ញុំមានដោយសារយាយខ្ញុំនៅរស់គាត់តែងតែនិយាយជាមួយខ្ញុំ។
ខ៖ បើសិនជាយើងថាមិនទៅទេយើងមានលុយមានមាសយើងជួលគេទៅ។
ក៖ ជួលគេទៅ។
ខ៖
គេមិនបង្ខំយើងចេះចុះទេដឹងតែអ្នកឯងទៅដឹងតែទៅអីទេអ្នកណាដែលអត់លុយអីក៏ស៊ីឈ្នួរគេទៅ។
ក៖ បាទ។
ខ៖ ចាំប៉ុន្នឹង។
ក៖
ដោយសារយាយខ្ញុំគាត់ដូចជាគាត់មានវិបត្តផ្លូវចិត្តអីចឹងគាត់តែងតែឃើញខ្ញុំដើរលេងនៅពេលល្ងាចៗៗអីចឹងគាត់តែងតែចងចាំទិដ្ឋភាពសនយ័និងគាត់ថាចៅឯងកំដើរលេងពេលល្ងាចច្រើនពេកប្រយត្តគេចាប់។
ខ៖ ចាំ។
ក៖
គាត់ចេះតែនិយាយពាក្រនិងហើយខ្ញុំចេះតែឆ្ងល់គេចាប់អីគេឃើញមានណាចាប់អីទៀតឥលូវនិង។
ខ៖ គេចាប់ចេះក្មួយឥលូវនិងវាដូចថាអ្នកជក់ថ្នាំញៀនអីនិង។
ក៖ បាទ។
ខ៖ ឃើញយើងល្អជាចឹងអាចញៀនថ្នាំវាចាប់យើងយកទៅបញ្ចុក។
ក៖ បាទ។
ខ៖ អាថ្នាំញៀណ។
ក៖ បាទ។
ខ៖ អាព្រោះឥលូវនិងអាខាងចឹង។
ក៖ បាទ។

ខ៖
ឥលូវនិងវាពិបាកជាទីរបំផុតអារឿងអាថ្នាំញៀឈានិងឥលូវដល់ពេលបែកអីចឹងទៅវាលែងដឹង
អីឡើៗៗៗ។
ក៖
អ៊ំដែលអ៊ំដែលលឺពីប្រជាជនខ្មែរយើងនិយាយអំពីអាពាក្រពេញនិយមនៅក្នុងសមយ័ករប្រាំគេ
ថាទៅជិះឡានមកវិញជិះចានដែលលឺដែលលឺពាក្រនិងអត់?
ខ៖ អានិងចឹងតើ។
ក៖ បាទ។
ខ៖ ចាំ ។
ក៖ ទៅចិះឡានមកវិញជិះចានជិះអាចានធាតុនិងមែនអ៊ំ?
ខ៖ និងជិះចានធាតុនិងហើយ។
ក៖ ចឹងមាននយ័ថាមនុស្សស្លាប់បាត់ទៅហើយ។
ខ៖ និងហើយមនុស្សស្លាប់បាត់។
ក៖ និងដោយសារខ្ញុំគ្រាន់តែចង់បានកាលនិយាយភស្តុតាងនិង។
ខ៖ ចាំ។
ក៖ សំរាប់មនុស្សជំនាន់ក្រោយគេដឹងថាអីរព្រឹត្តិការណ៍ទាំងអស់និងមែនចេះតែប្រឌិតឡើង។
ខ៖ មែនទេវាសុទ្ធតែជារឿងការពិត។
ក៖ បាទ។
ខ៖ ចាំ រឿងសុទ្ធតែការពិតហើយអត់មានកុហាកអត់មានអីទេ។
ក៖ បាទ។
ខ៖ រួចដល់ពេលសង្គមយើងឥលូវនេះពិបាករឿងថ្នាំញៀន។
ក៖ បាទ។
ខ៖ ថ្នាមញៀនជល់មាន់។
ក៖ បាត។
ខ៖ ចាំ។
ក៖
អញ្ចឹងផុតដល់សមយ័និងមកទៅខ្ញុំភ្លេចសួរអំពីសំនួរមួអំពីការរៀបការរបស់អ៊ំហើយប្តីរបស់អ៊ំ
កើតចេញពីការផ្សំផ្គុំពីឪពុកម្តាយឬក៏កើតចេញពីការស្រលាញ់។
ខ៖ ម៉ែឪទុកដាក់។
ក៖ ទុកដាក់។
ខ៖ ចាំ ម៉ែឪទុកដាក់កាលជំនាន់និងមានមានតែមេក្រូអត់ភ្លេង។

កៈ បាទ។
ខៈ ចាំ ហើយថតថតមានតែអត់មានខូលើរទេមានតែសខ្មៅ។
កៈ សខ្មៅនិងទេ។
ខៈ ចាំ ។
កៈ តែបានម៉ាថតដែល?
ខៈ ចាំបានថតបានអីនិង។
កៈ មាននៅសល់រូបថតចាសៗទាំងអស់និងអត់?
ខៈ អ៊ើរ កាលជំនាន់អាពតនិងអស់ហើយ។
កៈ ទៅអស់ហើយ ចឹងជំនាន់អាពតនិងពិតជាចង្រៃមែន។
ខៈ អស់ហើយអត់មានត្រូវការអីទុក។
កៈបាទ។
ខៈ
រូបថតរូបអីពីណាគេវាយកចោលមានទឹកអប់អីថាស្អីស្អីគេជំរុះកាកសំណល់អីគេវាអាពតវាយកអស់ហើយ។
កៈ បាទ។
ខៈ រួចដល់យកទៅវាលាបខ្លួនវា។
កៈ បាទ។
ខៈ មានមាសមានអីវាយកទៅដាក់កន្ត្រកអី។
កៈ ពិធីការនៅក្នុងសមយ័និងរយៈពេលប៉ុន្មានថ្ងៃដែល?
ខៈ មួយយប់មួយថ្ងៃនិងក្មួយឯង។
កៈ អ្នកមាននិងអ្នកក្រធ្វើដូចគ្នា?
ខៈ ដូចគ្នា។
កៈ ដូចគ្នា។
ខៈ ចាំ ។
កៈ អត់មានអ្នកណាធ្វើទៅដល់បីថ្ងៃឬក៏ប្រាំពីថ្ងៃ?
ខៈ អត់ទេល្ងាចឡើងសូត្រមន្តស្អែកឡើងហូបអីទៅមានធុងបាសធុងអីនិង។
កៈ ព្រលឹមឡើងហូបល្ងាចឡើងចូលរោង។
ខៈ ចាំ ហើយទៅចប់។
កៈ
ដោយសារផ្លូវល្ងាចៗឡើងមានញាំអីហើយមានកាត់នំទៀតសមយ័មុនមានកាត់ចឹងអត់?
ខៈ អត់ អានិងវាស៊ីសងរឿងលុយតើ។

ក៖ សងលុយ។
ខ៖ ចាំ ស៊ីសងរឿងលុយ បើយើងអត់មានលុយ។
ក៖ ការកាត់អីនិងជាវប្បធម៌បរទេសតើអ៊ំវាមិនមែនជាវប្បធម៌ខ្មែរពីមុន?
ខ៖
អានេះស៊ីសងទោះសព្វថ្ងៃធ្វើអ្នកណាគេមានលុយក៏កាត់នំខេយទៅអ្នកណាអត់លុយទេគ្រាន់ធ្វើធុងបាសឬមួយក៏អកកេសរាំទៅ។
ក៖
តែអាការកាត់និងវាជាវប្បធម៌ដែលយើងរៀនពីខាងក្រៅមកឬក៏វាជាវប្បធម៌ខ្មែរពីដើមមកចឹង?
ខ៖ ទេពីជំនាន់ខ្ញុំអត់មានពីណាកាត់នំខេយនំអីផងគ្រាន់។
ក៖ មានផ្លែឈើ។
ខ៖បុកលាក់
ក៖ បុកលាក់។
ខ៖ បុកលាក់បុកអីចឹងទៅអត់មានធុងបាសអកកេសធុងអីទេ។
ក៖ បាទ។
ខ៖ ចាំ ។
ក៖ តែមានការរាំវែកសប្បាយអីអត់?
ខ៖ រាំទៅដូចតែស្គរដៃស្គរអីទៅអាចមានចុះតលូវសម័យគេចេះតែជឿនលឿន។
ក៖
មានសំនួររៀងអស់សំនើចបន្តិចតើសម័យនិងកាលពេលដេលការហើយភ្លាមគេសម័យឥលូវគេមានពាក្រថាហាន់នីមូនចឹងក្រោយពេលការទៅគេតែងតែហៅហាន់នីមូនគេទៅកន្លែងណាមួយដែលសប្បាយៗទៅកំពង់សោមឬក៏ទៅប្រទេសថៃប្រទេសអីចឹង។
ខ៖ ចាំ។
ក៖ ចុះសម័យមុននៅពេលដែលការភ្លាមមាននាំប្រពន្ធឬក៏ដៃគូរអីដើរលេងអីនៅសៀមរាបអី?
ខ៖ អត់ទេទៅដើរលេងណាគិតតែការរួចខំតែត្បាញខំរវៃចញ្ចឹមជិវិត។
ក៖ បាទ។
ខ៖ យើងមានប្រាក់ខែប្រាក់ថ្ងៃអីណា។
ក៖
បាទអ៊ំនៅពេលដែលប្ដីរបស់អ៊ំគាត់ធ្លាប់ទៅធ្វើនៅសម័យកប្រាំត្រូវទេអ៊ំធ្វើទាហាននៅសម័យនិង?
ខ៖ ប្ដីរបស់ខ្ញុំអត់ដែលធ្វើទាហានអីផង។
ក៖ អត់ដែលធ្វើទាហានអីទេ។

ខ៖ ចា៎ ។
ក៖ ហើយ។
ខ៖ បើក៏ប្រាំគាត់ជួលគេ។
ក៖
ក្តីសុបិន្តដ៏ធំបំផុតតាំងពីវយ័កុមាររហូតមកដល់ឥលូវនិងការងារអីគេខ្លះក្តីសុបិន្តអីគេខ្លះដែលអ៊ំចង់ធ្វើ?
ខ៖ មានអី។
ក៖ ក្រៅពីតំបាញអ្នកតំបាញ។
ខ៖ មានអីមានតែត្បាញមានតែធ្វើ។
ក៖ អត់ដែលមានក្តីសុបិន្តថាអ៊ំរបើក្លាយជាគ្រូបង្រៀនប្រហែលជាល្អជាងអីចឹង?
ខ៖ គ្រូបង្រៀនអីណាបើយើងរៀនអត់ដល់ផង។
ក៖ តែដូចជាក្តីនៅពេលដែលនៅតូចៗយើងមិនទាន់បានធ្វើការណា។
ខ៖ ចា៎។
ក៖ យើងមានតែក្តីសុបិន្តធ្លាប់មានក្តីសុបិន្តណាចង់ធ្វើអីមួយ?
ខ៖ អត់មានចង់ធ្វើអីមួយទេព្រោះអីម៉ែឪក្រ។
ក៖ម៉ែឪក្រ។
ខ៖ ចា៎ ។
ក៖
រួចដូចចៅខ្ញុំសព្វថ្ងៃនេះគេសុបិន្តថាគេចង់ទៅរៀននៅប្រទេសក្រៅព្រោះគេតែម៉ែឪគេគិតតែអោយខំៗរៀនប៊រចំនេកខ្ញុំនិងគឺអត់មានកឺខំប្រឹងរៀនអីទេម៉ែឪក្រនិង។
ក៖ បាទ។
ខ៖ ចា៎ ។
ក៖ ចុះអ៊ំគិតថាឆ្នាំណាដែលប្រទេសខ្មែរយើងចាប់ផ្តើមបិវត្តការចាយលុយជាទូទៅឡើងវិញ?
ខ៖ ដឹងអីទេក្មួយអើយខ្ញុំអត់សូវដឹងដែលរឿងនិង។
ក៖ អត់សូវដឹងដែល។
ខ៖ ចា៎
ខ្ញុំអត់សូវដឹងដែលប៉ុន្តែដូចជាបែកអាពតឃ្យូឬក៏ឆាប់ចាប់ផ្តើមមានលុយមានចាយលុយប្រាំរយមួយពាន់អីនិង។
ខ៖ កាលនិងចាយលុយចាយុយបីរយការនិងបីរយនិងមាសម៉ាតម្លឹង។
ក៖ មាសមួយតម្លឹង។
ខ៖ ចា៎ បីរយនិងនៅចាយលុយវៀតណាមនិងកាលនិង។

កៈ បាទចាយលុយដុងនិងចឹង។
ខៈ ចា៎ ។
កៈ
ចុះមានព្រឹត្តិការណ៍ណាដែលគួរអោយខ្លាចអីទៀតទេបន្ទាប់ពីសមយ័កប្រាំមានព្រឹត្តិការណ៍ដែលគួរអោយខ្លាចអីទៀតអត់?
ខៈ ខ្លាចហ្មេះក្មួយអើយខ្លាចអារឿងខ្លាចវិលដូចអាពតនិងទៀតនិង។
កៈ បាទ។
ខៈ ចា៎ ។
ខៈ
អាពតវាថានេ៎បានអាវពណ៍កំភ្លេចអាវខ្មៅប្រយត្តស្អីអាពតជីកទៅម៉ារណ្តៅប៉ុន្មានអ្នកម៉ារណ្តៅ១០អ្នក២០អ្នក។
កៈបាទ
ខៈ ខ្ញុំខ្លាចវានិយាយចឹងនិងណា។
កៈ ចេះតែខ្លាចថាវានិងវិលមកវិញ?
ខៈ ចា៎
ខ្ញុំខ្លាចចឹងនិងណាកំអោយតែមានកើតទៀតអីលោកអើយលោកស្រុកគេឥលូវនេះសម្បូរហូរហៀរ។
កៈ បាទ។
ខៈ ហូបក៏មិនអស់។
កៈ បាទ។
ខៈ ស្លៀកពាក់ក៏មិនអស់។
កៈ បាទ។
ខៈ ប្រឹងសម្បូរអីទៀតទេកង់លេងជិះហើយជិះសុទ្ធតែឡានជិះម៉ូតូសុទ្ធតែទំនើបៗៗ។
កៈ បាទ។
ខៈ កំអោយទៅបកក្រោយវិញទៀត។
កៈ បាទ។
ខៈ
ចេះតែអោយទៅមុខជំនាំអីដូចជាចេកហូបមិនអស់ចិត្តហាលជំនាប់ហាលអីជឹងសំបូររបៀបម៉ិចទៀតទេ។
កៈ ចុះអត់មានភិតភៃថានិងត្រលប់មកវិញនៅសមយ័ពុលពតនៅពេលសមយ័៩៧និងទេ។
ខៈ ចា៎និងចៃក។

ក៖ កាល៩៧មានការបាញ់គ្នានៅភ្នំពេញដែលមានលឺសំលេងគ្រាប់អីទេ?
ខ៖ កាលនិងលឺថាផ្ទុះនិងហើយចាំ។
ក៖ បាទ។
ខ៖ ផ្ទុះភ្នំពេញមិនដឹងមកខាងណាណៃខ្ញុំអត់សូវដឹងដែល។
ក៖ បាទ។
ខ៖
តែដល់ពេលដែលផ្ទុះភ្នំពេញនិងគេក៏អោយពួកអ្នកនៅភ្នំពេញនិងជំលៀសពីភ្នំពេញនិងចេញពីភ្នំពេញនិងចេញមកតាមជនបទ។
ក៖ បាទ
តែបាញ់គ្នាបានត្រឹមតែមួយថ្ងៃនិងពេលនិងកាលពេលនិងក៏ហើយរហូតទៅក៏ចចរចារគ្នា។
ខ៖ ពេលនេះពេលនិងក៏ងាប់មិនតិចដែលអាគ្រាប់អាអីនិង។
ក៖ បាទ។
ខ៖ និងមានរបួស។
ក៖ បាទ។
ខ៖ មានមួយនោះមានរបួសនៅភ្នែកនិងមិនទាន់បាត់ផង។
ក៖ បាទ ។
ខ៖ត្រូវគ្រាប់។
ក៖ គឺពេលនិងគឺការបាញ់គ្នារវាងគណ បក្រហ្វុនសិនប៉ិចនិងបក្រប្រជាជនកម្ពុជា។
ខ៖ ចាំ ។
ខ៖
ពេលទាហ៊ានវានៅវាដោះមិនដោះអីមិនទាន់ហើយដល់ពេលហើយពេលដើរទៅមានការផ្ទុះមិនផ្ទុះអីនៅតាមផ្លូវនៅតាមអីនិង។
ក៖ បាទ។
ខ៖ កាលនិង។
ក៖
បាទអញ្ចឹងចង់រៀបរាប់បន្តិចអោយបានច្បាស់ទីរកន្លែងរស់នៅបច្ចុប្បន្នរបស់អ៊ំឥលូវនិងពិតទាំងឈ្មោះភូមិស្រុកនិងអោយច្បាស់ជាងនិងបន្តិចឥលូវនិងអ៊ំរស់នៅកន្លេងណាដែល?
ខ៖ ឥលូវនិងខ្ញុំរស់នៅកោះដាច់យើងនិង។
ក៖ កោះដាច់ភូមិអីគេសង្កាត់អីគេដែលខណ្ឌអីគេដែល?
ខ៖ សង្កាត់ខណ្ឌជ្រោយចង្វារ។
ក៖ ខណ្ឌជ្រោយចង្វារ។

ខ៖ ចាំ។
ក៖ ទីក្រុង។
ខ៖ ឃំកោះដាច់។
ក៖ ឃុំកោះដាច់។
ខ៖ ចាំ ។
ក៖ ទីក្រុងភ្នំពេញ។
ខ៖ ខណ្ឌជ្រោយចង្វារភ្នំពេញ។
ក៖ ទីក្រុងភ្នំពេញ។
ខ៖ ឥលូវគេកាត់ចូលក្រុងហើយណា។
ក៖ បាទ។
ខ៖ ចាំ។
ក៖ ចូលក្រុងភ្នំពេញហើយ។
ក៖ អញ្ចឹងមានចៅប៉ុន្មានអ្នហើយអ៊ំ។
ខ៖ ចៅខ្ញុំច្រើន។
ក៖ ច្រើន។
ខ៖ ចៅខ្ញុំពីរដណ្តប់អ្នកហើយ។
ក៖ ១២អ្នកហើយ។
ខ៖ ចាំ ។
ក៖ ច្រើនគួរសមណាដែលអ៊ំ។
ខ៖ ចាំ ។
ក៖ ឥលូចឆ្នាំ២០១៨មានចៅ១២អ្នកច្រើន។
ខ៖ ដែកមួយពោះប្រាំមួយពោះបី។
ក៖ បាទអ៊ំបាទអ៊ំអញ្ចឹងក្នុងជិវិតនិងអ៊ំស្អប់អីជាងគេដែលខ្ញុំភ្លេចសួររឿងមួយនិង?
ខ៖ ខ្ញុំមួយជិវិតនិងខ្ញុំស្អប់អាពត។
ក៖ ស្អប់អាពតជាងគេ។
ខ៖ ចាំ។
ក៖ ប្រភេទសត្វអីដែលខ្លាចជាងគេ?
ខ៖ អ៊ីរ។
ក៖ ដូចជាខ្ញុំខ្លាចសត្វតុកែអ៊ំខ្លាចអីជាងគេ?
ខ៖ ខ្ញុំខ្លាចជាងគេខ្លាចពស់។
ក៖ ខ្លាចពស់។

ខ៖ ពស់វែកអីនិងខ្ញុំខ្លាច។
ក៖ ពស់វែកអីនិងខ្លាចជាងគេ។
ខ៖សត្វមានពិស។
ក៖ បាទ។
ខ៖ ក្អែបអីនិងសុទ្ធតេខ្លាចហើយ។
ក៖ បាទអ៊ំបាទអ៊ំ។
ខ៖ ខ្លាចតែរបស់មានពិស។
ក៖
អញ្ចឹងខ្ញុំអស់សំនួរដើម្បីសួរអ៊ំអំពីជីវប្រវត្តរបស់អ៊ំហើយប៉ុន្តែខ្ញុំមានសំនួរមួយជាសំនួរដើម្បីង អោយអ៊ំផ្តាំផ្ញើរសំរាប់អ្នកដែលបានលឺសំលេងនិងដូចជាកូនអ៊ំចៅអ៊ំក្មួយអ៊ំឬក៏មនុស្សដែលកើត ជំនាន់ក្រោយៗទៀតដែលបានលឺសំលេងមួយនិងអ៊ំមានអីផ្តែរផ្តាំសំរាប់ពួកគេទេ?
ខ៖
ខ្ញុំផ្តាំផ្ញើរកូនក្មួយទាំងអស់ដើម្បីអោយខំប្រឹងរៀនប្រឹងសូត្រកំអនុវត្តតាមថ្នាំញៀនថ្នាំអីនិងខុស ។
ក៖ បាទ។
ខ៖ ព្រោះស្រុកទេសយើងសម្បូរសប្បាយហើយ។
ក៖ បាទ។
ខ៖ អោយបានសុខរហូតទៅ។
ក៖ បាទ។
ខ៖ ចាំ។
ក៖ អញ្ចឹងពាក្រផ្តាំផ្ញើររបស់អ៊ំពិតជាល្អមែនទែនសំរាប់មនុស្សជំនាន់ក្រោយៗ។
ខ៖ ចាំ។
ក៖ ការសិក្សារខិតខំប្រឹងប្រែងរៀនសូត្រដែលជាស្ពានមួយ។
ខ៖ ខំប្រឹងប្រែងរៀនសូត្រ។
ក៖ ដែលនាំជិវិតទៅប្រសើរហើយមួយទៀតគឺជៀសអោយផុតពីអំពើឧបាយមុខ។
ខ៖ ចាំ ។
ក៖ ផ្សេងៗៗនិងមាន។
ខ៖ គ្រឿងញៀនអីនិងមានតែការសិក្សារដែល។
ក៖ ដែលអាចនាំជិវិតទៅប្រសើរឡើង។
ខ៖ ចាំ។
ក៖ អញ្ចឹងអ៊ំមានអីបន្ថែមទៀតអត់អ៊ំ?

ខ៖ ខ្ញុំមានតែប៉ុន្នឹង។
ក៖ មានតែប៉ុន្នឹង។
ខ៖ ចា៎។
ក៖ អញ្ចឹងខ្ញុំសូមអរគុណអ៊ំ
ខ៖ ចា៎។
ក៖
ដែលបានផ្តល់ការសំភាសន៍នៅថ្ងៃនិងហើយក៏អគុណច្រើនសំរាប់ការផ្តល់ពេលវេលាសំរាប់ថ្ងៃនិង។
ខ៖ ចា៎។
ក៖ អញ្ជឹងខ្ញុំសូមអរគុណហើយខ្ញុំអស់ហើយចឹងខ្ញុំបិទការសំភាសន៍។
ខ៖ចា៎។
ក៖ នៅត្រឹមនិង៕